| ៣-លោក | លាង | ផល្លី | ប្រធានការិយាល័យ |
| ៤-លោក | ណោ | ជីវ័ន្ត | មន្ត្រី |
| ៥-លោក | តុប | ហ្វ្រង់ស្វ័រ | ជំនួយការ |
| ៦-លោក | ស្រ៊ិន | សុវណ្ណ | ជំនួយការ |
| ៧-លោក | យ៉ុន | ឧត្តមវង្សវិចិត្រ | ជំនួយការ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.-**

បំពាក់ **មេដាយមាសការងារ** ជូនលោក **ហ៊ឹម សុខម៉េត** មន្ត្រីនៃនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុទំនាក់ទំនងផែនការ និងនីតិកម្ម ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងប្រធានអាជ្ញាធរជាតិព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

68

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៧...អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានផ្ទេរភារកិច្ចលោក **សោម ខាន់ដា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ឲ្យទៅកាន់តំណែងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

4

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៤ . អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០៤ រូប ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ | |
|---|---|---|---|
| | | ចាស់ | ត្រូវដំឡើង |
| ១ | លោក **សាន ហួត** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ២ | លោក **អ៊ុក ធាវី** | ពីអនុមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៣ | លោក **តូច ណារ័ត្ន** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៤ | លោកជំទាវ **ប្រាក់ អេលីរតនា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៤៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ឆ៉ាន់ខែម ប៊ុនថន** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើប្រធាននាយកដ្ឋាន។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៦ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

# សម្រេច

**មាត្រា ១.-** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០៣ រូប ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ | |
|---|---|---|---|
| | | ចាស់ | ត្រូវដំឡើង |
| ១ | ឯកឧត្តម **ស៊ុន សាខន** | ពីអនុមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២ | ឯកឧត្តម **សោម សាត** | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៣ | លោក **លន់ ហួរ** | ពីអនុមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧៨ អនក្រ.បក

# អនុក្រឹត្យ

ស្ដីពី

# ការដំឡើងឋានន្តរស័ក្ដិនាយនគរបាលជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីសហលក្ខន្តិកៈនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានដំឡើងឋានន្តរស័ក្ដិថ្នាក់ **ឧត្ដមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **អ៊ឹម ធឿន** អត្តលេខ ០៥៥០៩ នាយនគរបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៨ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការតែងតាំងមុខងារ នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ៈ** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ទោ **ចៅ យុត្តិបុត្រ** | អត្តលេខ ០១១៥៨៨ | ជា នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ២-ឧត្តមសេនីយ៍ទោ **យូ សិរីវុឌ្ឍ** | អត្តលេខ ០១៩៧០៣ | ជា នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ៣-ឧត្តមសេនីយ៍ទោ **ណឹម បញ្ញាវុធ** | អត្តលេខ ០០១៥៥១ | ជា អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស |

៤-ឧត្តមសេនីយ៍ទោ **ចៅ តិរិទ្ធ** អត្តលេខ ០១៣៩២០ ជា អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **គន ឡឿន** ព្រះចៅអធិការវត្តត្រពាំងសំបួរថ្មី បានខិតខំយកអស់កម្លាំងព្រះកាយ ចិត្ត ក្នុងការដឹកនាំកសាងវត្ត និងបរិច្ចាគធនធានផ្ទាល់របស់ព្រះអង្គ ជួយកសាងព្រះវិហារ ឧបដ្ឋានសាលា កុដិ របងវត្ត និងសមិទ្ធផលនានា នៅវត្តត្រពាំងសំបួរថ្មី ស្ថិតនៅក្នុងឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ចំណាយអស់ថវិកាសរុបចំនួន ៥៤.៥៤០ ដុល្លារអាមេរិក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៤
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ពាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយស្ពាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៤រូប ដែលបានចូលរួមឧបត្ថម្ភថវិកា និងសំភារៈជួយកសាងអគ្គភាពតំបន់ប្រតិបត្តិការសឹករងកោះកុង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ពាបនាជាតិ**

-វរសេនីយ៍ត្រី **ណោខ ទ័ាន់** មេបញ្ជាការផ្នែកសឹករងថ្មបាំង តំបន់ប្រតិបត្តិការសឹករងកោះកុង ថវិកាចំនួន ១២.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ពាបនាជាតិ**

១-អនុសេនីយ៍ទោ **ថន ឃិន** មេបញ្ជាការរងផ្នែកសឹករងស្រែអំបិល តំបន់ប្រតិបត្តិការសឹករងកោះកុង ថវិកាចំនួន ៦.០០០ ដុល្លារ

២-លោកជំទាវ **សិត បុឡា អ៊ុន នាលី** សប្បុរសជន ថវិកាចំនួន ៥.៥០០ ដុល្លារ

៣-លោក **ហាយ ស៊ីន** មេឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ថវិកាចំនួន ៥.៥០០ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-ឧត្ដមសេនីយ៍ត្រី | **ហ៊ីរ ហាប់** | អគ្គលេខាធិការរងសន្តិសុខលំហសមុទ្រ | ថវិកាចំនួន ១.១០០ ដុល្លារ |
| ២-លោក | **អន តារៈ** | អភិបាលស្រុកបូទុមសាគរ ខេត្តកោះកុង | ថវិកាចំនួន ១.១០០ ដុល្លារ |
| ៣-លោក | **សោម សុធីរ** | អភិបាលស្រុកកោះកុង | ថវិកាចំនួន ១.១០០ ដុល្លារ |
| ៤-លោក | **ថន គៃត** | សប្បុរសជន ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង | ថវិកាចំនួន ២.០០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:......០៥......សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកំណត់របៀបរបបការងារ និង ការបែងចែកភារកិច្ច របស់រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុជ គីមអន** ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : ប្រគល់ភារកិច្ចជូនឯកឧត្តម **អ៊ុជ គីមអន** ឲ្យទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងការសម្របសម្រួលទំនាក់ទំនងការងារជាមួយស្ថាប័នអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការអន្តររដ្ឋាភិបាលនានា(លើកលែងអាស៊ាន) និងអង្គការគណបក្សនយោបាយអន្តរជាតិ ។

**ប្រការ ២** : ឯកឧត្តម **អ៊ុជ គឹមអន** ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៣** : ឯកឧត្តម **អ៊ុជ គឹមអន** មានជំនួយការ ៤រូប ក្នុងនោះ ១រូប មានឋានៈស្មើ អគ្គនាយក, ១រូប មានឋានៈស្មើអគ្គនាយករង និង ២រូប មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**ប្រការ ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥** : ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ដូចប្រការ ១ និង ប្រការ ៥*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:**...០៦...ស.សរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះក្រឹត្យលេខ នស/រកត/ ០៨០៥/៣៨៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៤ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោកជំទាវវេជ្ជ. | **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ប្រធាន |
| ២-លោកជំទាវ | **ឌុ ម៉ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-លោកជំទាវ | **ហ៊ុ សាមិត្ត** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | **ថាច់ ផែន** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៦-លោកជំទាវ | **ឆាយ ម៉ាន់ឡើន** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកា |
| ៧-លោកជំទាវ | **ឡូន សុខា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកា |
| ៨-លោកជំទាវ | **អ៊ូ ច័ន្ទី** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិកា |
| ៩-លោកជំទាវ | **តាន់ ឌួចឆេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិកា |
| ១០-លោកជំទាវ | **ស៊ើង សរសុចិត្តា** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ១១-ឯកឧត្តម | **ណាត ម៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២-លោកជំទាវ | **ម៉ាត់ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិកា |
| ១៣-លោកជំទាវ | **ម៉ិញ គុសនី** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិកា |
| ១៤-លោកជំទាវ | **សម មុន្នីកា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិកា |
| ១៥-លោកជំទាវ | **ម៉ែន សុបតា** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិកា |
| ១៦-លោកជំទាវ | **ហោ ម៉ាលីន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកា |
| ១៧-លោកជំទាវ | **ឡាយ ណារីន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិកា |
| ១៨-លោកជំទាវ | **តឹករ៉េត កំរេង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិកា |
| ១៩-លោកជំទាវ | **ឃុន លក្សី** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិកា |
| ២០-លោកជំទាវ | **ស៊ឹម ខេងខាំ** | អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | សមាជិកា |
| ២១-លោកជំទាវ | **សុទ្ធ សុម៉ាលី** | អនុប្រធានគណៈកម្មាធិការសិទ្ធមនុស្សកម្ពុជា | សមាជិកា |
| ២២-លោកជំទាវ | **ខៀវ មុរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ២៣-ឯកឧត្តម | **ជុក មុន្នី** | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ២៤-លោកជំទាវ | **ញៀម សុភាព** | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិកា |
| ២៥-លោកជំទាវ | **ទូច ផានី** | ទីប្រឹក្សាឯកឧត្តមឧប. **ហោ ណាំហុង** | សមាជិកា |

**ប្រការ២ ._**

ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានភារកិច្ចអនុវត្តទៅតាមការតម្រង់ទិសនៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៨៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល ព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។ អនុប្រធាននិសមាជិកត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៣ ._**

សេចក្តីសម្រេចលេខ១១ សសរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...០៧២...សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំង ចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ
- បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលគណៈកម្មាធិការ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## សម្រេច

**ប្រការ ១:** កែសម្រួលសមាសភាពគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដូចតទៅ ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ប្រាក់ សុខុន | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២-ឯកឧត្តម ម៉ឹង សំផន | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ុច បូររិទ្ធ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម ជូ គីមឡេង | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥-ឯកឧត្តម យឹម រស្មីដា | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៦-ឯកឧត្តម សែម សុវណ្ណនី | អគ្គនាយក មជ្ឈមណ្ឌលជាតិ | អនុប្រធាន |
| ៧-ឯកឧត្តម ណឹម សុវត្ថិ | ទីប្រឹក្សានិងជានាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ | សមាជិកអចិន្ត្រៃយ៍ |
| ៨-ឯកឧត្តម សុខ ផេង | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ៩-ឯកឧត្តម ស្លូត សំបូរ | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០-ឯកឧត្តម ប៊ុន នី | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១១-ឯកឧត្តម សំ វណ្ណថន | អគ្គលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១២-ឯកឧត្តម ស៊ុំ សំណាង | អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ | សមាជិក |
| ១៣-ឯកឧត្តម ចៅ ភីរុណ | អគ្គនាយក អគ្គនាយកដ្ឋានសំភារៈ-បច្ចេកទេសក្រសួងការពារជាតិ | សមាជិក |
| ១៤-ឯកឧត្តម មាស សាវ៉ន | អគ្គនាយក អគ្គនាយកដ្ឋានយោធសៅ ក្រសួងការពារជាតិ | សមាជិក |
| ១៥-ឯកឧត្តម ជាំ វុទ្ធី | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៦-ឯកឧត្តម មាស សំអុល | នាយក នាយកដ្ឋានបុគ្គលិកក្រសួងការពារជាតិ | សមាជិក |
| ១៧-ឯកឧត្តម វង្ស វិសនា | នាយកទីចាត់ការកេលយុទ្ធ កងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៨-ឯកឧត្តម តេង ឈួន | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក ។ |

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៩.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តកណ្តាល** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ **ប៊ិន ឈិន** | ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ប្រធាន |
| ២. ឯ.ឧ **ស៊ិន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. ឯ.ឧ **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯ.ឧ **ប្រាក់ សុខុន** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៥. ឯ.ឧ **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៦. ឯ.ឧ **ឌុល គឿន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៧. ឯ.ឧ **ស្រ៊ី ថាមរុង្គ** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៨. ឯ.ឧ **សុខ ចិន្តាសោភា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៩. ឯ.ឧ **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០. ឯ.ឧ **សយ ស៊ីផុន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១១. ឯ.ឧ **លី ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២. ឯ.ឧ **ទី សុគន្ធ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣. ឯ.ឧ **ប៊ុន សំបូរ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤. ឯ.ឧ **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥. ឯ.ឧ **ឌុច សុវណ្ណារី** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១៦. ឯ.ឧ **ហេង តៃគ្រី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៧. ឯ.ឧ **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៨. ឯ.ឧ **អ៊ិន ចន្ថា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៩. ឯ.ឧ **សាត សាមី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២០. ឯ.ឧ **ម៉េង សក្តិធារ៉ា** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២១. ឯ.ឧ **ខៀវ មុត** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ២២. ឯ.ឧ **សុះ មុះសិន** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ២៣. ឯ.ឧ **អូស្មាន ហាស្សាន់** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៤. **លោកជំទាវ ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២៥. ឯ.ឧ **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៦. ឯ.ឧ **ភូង ស៊ីផាន** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ២៧. ឯ.ឧ **ហេ កាន់** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៨. ឯ.ឧ **ជា ជុន** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៩. ឯ.ឧ **ឈឿន ប៊ុណ្ណារ័ត្ន** | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣០. **លោកជំទាវ ដួង សារុន** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៣១. **លោកជំទាវ នាង ឆាយយ៉ាណា** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ៣២. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ៣៣. តំណាងក្រសួងព័ត៌មាន | | សមាជិក |
| ៣៤. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តកណ្តាល និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម*
*លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..០៩...សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា នៅ**រាជធានីភ្នំពេញ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ គាត ឈន់ | ឧបនាយករដ្ឋមន្ត្រីប្រចាំការ | ប្រធាន |
| ២. ឯ.ឧ យុន ហាំង | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣. ឯ.ឧ ឱម យ៉ិនទៀង | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៤. ឯ.ឧ អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៥. ឯ.ឧ ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៦. លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | អនុប្រធាន |
| ៧. ឯ.ឧ ហង់ ជួនណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៨. ឯ.ឧ ហ្សាការីយ៉ា អាដាម | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៩. ឯ.ឧ អុជ គឹមអន | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១០. ឯ.ឧ ម៉ៅ អាយុទ្ធ | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១១. ឯ.ឧ លឹម ស៊ីដេនីន | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២. ឯ.ឧ រស់ សុផាន់ | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៣. ឯ.ឧ ម៉ៅ ហាវណ្ណាល់ | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៤. ឯ.ឧ ឯក សុនចាន់ | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៥. លោកជំទាវ សុភ័ត្ត ផាវី | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១៦. លោកជំទាវ ម៉ិញ កុសនី | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៧. លោកជំទាវ ប៉ែន សុបភា | រដ្ឋលេខាធិការក្រសួងក្រសួងផែនការ | សមាជិក |
| ១៨. លោកជំទាវ យុន លក្សី | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៩. លោកជំទាវ ទូច សារ៉ុម | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ២០. ឯ.ឧ ងី តាយី | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២១. ឯ.ឧ នាង ផាត | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ២២. ឯ.ឧ អះម៉ាត់ យ៉ះយ៉ា | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២៣. ឯ.ឧ សាវ៉ាក់ ខាន់ | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៤. ឯ.ឧ ប៊ិន អ៊ុយ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៥. ឯ.ឧ ហ៊ី សោភា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២៦. ឯ.ឧ ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៧. លោកជំទាវ ហ៊ុន ដានី | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៨. ឯ.ឧ សួន ឈាងលី | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ២៩. ឯ.ឧ អ៊ាង សុផល្លែត | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៣០. លោកជំទាវ ចម និម្មល់ | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣១. ឯ.ឧ វេង សុទ្ធរុធ | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣២. លោកជំទាវ ទិត លីនដា | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៣៣. លោកជំទាវ ទុង សុគន្ធ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣៤. ឯ.ឧ យុន ជិនកេន | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣៥. តំណាងក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំរាជធានីភ្នំពេញ។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*<u>កន្លែងទទួល:</u>*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម*
*លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ..១០.សសរ.

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តបាត់ដំបង** ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯ.ឧ ស ខេង | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២. ឯ.ឧ កែ គឹមយ៉ាន | ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | អនុប្រធានទី១ |
| ៣. ឯ.ឧ អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤. ឯ.ឧ សក់ សេដ្ឋា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥. ឯ.ឧ នឹម ថូត | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦. ឯ.ឧ ប៉ុល លឹម | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧. ឯ.ឧ អ៊ុន វីរជាតិ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨. ឯ.ឧ អ៊ុង ស៊ាន | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩. ឯ.ឧ ជូ គឹមឡេង | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០. ឯ.ឧ សៅ ជីវន្ត | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១. ឯ.ឧ ឈួន ដារ៉ា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. ឯ.ឧ ហោង សុខគង់ | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៣. ឯ.ឧ ហ៊ី តាំងអេង | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤. ឯ.ឧ ប៊ុន ហ៊ាន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៥. ឯ.ឧ នូវ សុវត្ថិ | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៦. ឯ.ឧ អ៊ឹង ភិរុន | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៧. ឯ.ឧ យឹម សារិទ្ធ | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨. លោកជំទាវ ហ៊ី សាមិត្ត | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១៩. លោកជំទាវ ម៉ីប៊ុត វិទ្យា | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ២០. លោកជំទាវ ជួញ សុផៃ | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ២១. ឯ.ឧ កុល វិរក្ស | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ២២. ឯ.ឧ ទូច រិទ្ធី | អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២៣. ឯ.ឧ អេ សុភា | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៤. ឯ.ឧ កៅ ធារ៉ូ | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២៥. ឯ.ឧ កឹង មៅ | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៦. ឯ.ឧ ឱក តាភរិទ្ធិ | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៧. ឯ.ឧ ខិញ ហង្សហួន | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ២៨. ឯ.ឧ សាត សមុទ្រ | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៩. ឯ.ឧ ថោ សេដ្ឋាណា | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣០. ឯ.ឧ ឈុំ សុជាតិ | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |

៣១. **ឯ.ឧ ទូច វិសាលសុខ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
៣២. **ឯ.ឧ គិត សេង** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៣៣. **ឯ.ឧ គឹម សុភ័ណ** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក
៣៤. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តបាត់ដំបង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...០១...សរ.ណ...**

## សារាចរ
## ស្តីពី
## ការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល

ដើម្បីធានាការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិលបានឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះដូចខាងក្រោម៖

១. ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសារមន្ត្រីរាជការក្នុងតារាងទូទាត់បៀវត្សប្រចាំខែនីមួយៗ៖

- គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ ត្រូវផ្តល់ឯកសារស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និង គ្រួសារមន្ត្រីរាជការមកក្រសួងមុខងារសាធារណៈឱ្យបានមុនដំណាច់សប្តាហ៍ទី១នៃខែនីមួយៗ
- ក្រសួងមុខងារសាធារណៈ ត្រូវធ្វើការណែនាំលម្អិតអំពីបែបបទឯកសារតម្រូវនិងទម្រង់ឯកសារពាក់ព័ន្ធនឹងការស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និង គ្រួសាររបស់មន្ត្រីរាជការក្នុងតារាងទូទាត់បៀវត្សប្រចាំខែដល់គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ។

២. ការផ្តល់តារាងទូទាត់បៀវត្សប្រចាំខែនិងតារាងកាត់ពន្ធលើបៀវត្សប្រចាំខែដល់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ៖

- ក្រសួងមុខងារសាធារណៈ ត្រូវផ្តល់តារាងទូទាត់បៀវត្សប្រចាំខែនិងតារាងកាត់ពន្ធលើបៀវត្សប្រចាំខែទៅឱ្យគ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះយ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី២នៃខែនីមួយៗ ដើម្បីរៀបចំអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ
- ក្រសួងមុខងារសាធារណៈ ត្រូវផ្តល់ឯកសារចម្លងមួយច្បាប់នៃតារាងទូទាត់បៀវត្សប្រចាំខែនិងតារាងកាត់ពន្ធលើបៀវត្សប្រចាំខែទៅឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិនិងរតនាគាររាជធានី ខេត្ត)។

៣. ការរៀបចំអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ

- ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ ត្រូវរៀបចំអាណត្តិបើកប្រាក់បៀវត្សប្រចាំខែផ្អែកតាមតារាងទូទាត់បៀវត្សប្រចាំខែផ្តល់ដោយក្រសួងមុខងារសាធារណៈ
- អាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ត្រូវរៀបចំសម្រាប់តែចំណាយលើបៀវត្សតែប៉ុណ្ណោះ។

៤. ការពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ

៤.១ ថ្នាក់ក្រសួង ស្ថាប័ន

- ប្រធានស្ថាប័ន ក្នុងនាមជាអាណាប័កដើមខ្សែ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់លើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែឬ
- ប្រធានស្ថាប័ន អាចធ្វើប្រតិភូកម្មដល់អាជ្ញាធរក្រោមបង្គាប់ ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិដូចខាងក្រោម÷
    - អគ្គនាយក ឬអគ្គលេខាធិការទទួលបន្ទុកនាយកដ្ឋានហិរញ្ញវត្ថុ ឬអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ឬ
    - ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ឬ ប្រធានអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន។
- អាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលត្រូវបានចុះហត្ថលេខាដោយអាណាប័កនិងទទួលបានទិដ្ឋាការហើយពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) យ៉ាងយូរត្រឹមថ្ងៃទី៤នៃសប្តាហ៍ទី៣នៃខែនីមួយៗ។ ក្នុងករណីពុំទាន់មានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំនៅក្រសួង ស្ថាប័ន អាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ករួចហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) យ៉ាងយូរត្រឹមថ្ងៃទី៣នៃសប្តាហ៍ទី៣នៃខែនីមួយៗ។

៤.២ ថ្នាក់រាជធានី ខេត្ត

- អភិបាលនៃគណៈអភិបាល ក្នុងនាមជាអាណាប័កដើមខ្សែ ពិនិត្យ និង ចុះហត្ថលេខាដោយផ្ទាល់ឬប្រគល់សិទ្ធិដល់អភិបាលរង ដើម្បីពិនិត្យ និង ចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែសម្រាប់មន្ត្រីរាជការបម្រើការងារនៅសាលារាជធានី ខេត្ត សាលាខណ្ឌ ក្រុង ស្រុក ឃុំនិងសង្កាត់
- ប្រធានមន្ទីរឬអង្គភាពពាក់ព័ន្ធក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិពីប្រធានស្ថាប័ន ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ឬប្រគល់សិទ្ធិដល់អនុប្រធាន ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែសម្រាប់មន្ត្រីរាជការបម្រើការងារក្នុងមន្ទីរឬអង្គភាព
- អាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុយ៉ាងយូរត្រឹមថ្ងៃទី៤នៃសប្តាហ៍ទី៣នៃខែនីមួយៗ។

៥. ការបើកផ្តល់បៀវត្សដល់មន្ត្រីរាជការ÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិនិងរតនាគាររាជធានី ខេត្ត) ត្រូវចាត់ចែងការត្រួតពិនិត្យនិងរៀបចំបើកផ្តល់បៀវត្សដល់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះឱ្យបានទាន់ក្នុងសប្តាហ៍ទី៤នៃខែនីមួយៗបន្ទាប់ពីទទួលបានអាណត្តិបើកប្រាក់បៀវត្សប្រចាំខែតាមកាលកំណត់ខាងលើពីក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ
- ក្នុងករណីក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ មិនបានបញ្ជូនអាណត្តិបើកប្រាក់បៀវត្សប្រចាំខែដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមកាលកំណត់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិនិងរតនាគាររាជធានី ខេត្ត) ត្រូវចាត់ចែងបើកបៀវត្សដល់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ ដោយធ្វើការបុរេប្រទានសាច់ប្រាក់ផ្អែកតាមតារាងទូទាត់បៀវត្សប្រចាំខែដែលផ្តល់ដោយក្រសួងមុខងារសាធារណៈ ឱ្យបានទាន់

ពេលវេលាកំណត់ដោយចាត់ទុកថាក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធបាន ឯកភាពជាស្វ័យប្រវត្តិលើការទូទាត់បើកបៀវត្សប្រចាំខែនោះ ប៉ុន្តែក្រសួង ស្ថាប័ន សាលា រាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធ ត្រូវផ្តល់លិខិតយុត្តិការនិងអាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលចុះហត្ថលេខារួចដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកតាមករណីពាក់ព័ន្ធនីមួយៗ ដើម្បីធ្វើការទូទាត់ជិរះបញ្ជីបុរេប្រទាននោះតាមក្រោយឱ្យស្របតាមនីតិវិធីហិរញ្ញវត្ថុ

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំកំណត់បែបបទនិងនីតិវិធីហិរញ្ញវត្ថុសម្រាប់ថ្នាក់ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្ត ព្រមទាំងរៀបចំតារាងពេលវេលានៃការបើកផ្តល់បៀវត្សដោយកំណត់ថ្ងៃជាក់លាក់សម្រាប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះតាមលំដាប់លំដោយក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ។

៦. គណនេយ្យភាពនិងការទទួលខុសត្រូវ

- អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និង ចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែដូចដែលបានចង្អុលបង្ហាញខាងលើ ត្រូវចាត់ចែងបំពេញភារកិច្ចដោយផ្ទាល់ឬធ្វើប្រតិភូកម្មដល់អាជ្ញាធរស្ថិតក្រោមបង្គាប់ដើម្បីបំពេញការងារឱ្យទាន់ពេលវេលាកំណត់
- អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវអនុវត្តភារកិច្ចតាមខ្លឹមសារនៃសារាចរនេះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធផ្អែកតាមកម្រិតឋានានុក្រម និងមន្ត្រីរាជការដែលត្រូវទទួលបៀវត្សក្នុងខែនីមួយៗ ព្រមទាំងត្រូវមានការទទួលខុសត្រូវផ្សេងទៀតជាយថាហេតុផ្អែកតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

ទទួលបានសារាចរនេះគ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី ខេត្ត*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ០១ សរណន

## សារាចរណែនាំ

## ស្តីពី

## ការរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ឆ្នាំ ២០១៨

ទិវាវប្បធម៌ជាតិ៣មីនា គឺជាទិវាដ៏មានសារៈសំខាន់មួយរបស់ព្រះរាជាណាចក្រកម្ពុជា ដែលរាជរដ្ឋាភិបាលតែងតែបានយកចិត្តទុកដាក់រៀបចំឡើងជារៀងរាល់ឆ្នាំ ក្នុងគោលបំណង រំលឹកដល់គុណូបការៈដ៏ធំធេងនៃបុព្វបុរសរបស់យើង ដែលបានបន្សល់ទុកនៅសម្បត្តិវប្បធម៌ ដ៏សម្បូរបែបសម្រាប់យើងគ្រប់គ្នាជាកូនចៅជំនាន់ក្រោយ និងជាទិវាបង្កើននូវសេចក្តីស្រឡាញ់ ព្រមទាំងស្មារតីចូលរួមថែរក្សា ការពារ សម្បត្តិវប្បធម៌ទាំងនេះឲ្យឋិតថេរគង់វង្ស ។

ដូចយើងទាំងអស់គ្នាបានដឹងហើយថា សម្បត្តិវប្បធម៌ ដែលបានកើតចេញពីការ ខិតខំប្រឹងប្រែងនៃបុព្វបុរសរបស់យើងទាំងអស់នេះ គឺជាដួងព្រលឹង ជាអត្តសញ្ញាណប្រកប ដោយកិត្យានុភាពជាតិ ជាមរតកប្រកបដោយសក្តានុពលដ៏ធំធេងបំផុត ក្នុងការរួមចំណែក អភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងជាមូលដ្ឋានក្នុងការផ្សារភ្ជាប់ទំនាក់ទំនងដ៏រឹងមាំពីសង្គមមួយទៅ សង្គមមួយ ពីក្រុមមួយទៅក្រុមមួយ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ឲ្យចេះរួមរស់ជាមួយគ្នា ប្រកបដោយសុខដុមភាព និងគ្មានការរើសអើង។ ហេតុនេះហើយ ក្នុងនាមយើងទាំងអស់គ្នា ដែលជាទាយាទ ត្រូវតែបំពេញកាតព្វកិច្ចក្នុងការធានាឲ្យបាននូវសុខដុមភាពនៃពហុវប្បធម៌ ជាតិ តាមរយៈការយកចិត្តទុកដាក់ថែរក្សា ការពារ និងអភិវឌ្ឍ តាមរយៈការបណ្តុះបណ្តាល ការផ្សព្វផ្សាយ ការផ្ទេរចំណេះជំនាញបច្ចេកទេស និងទេពកោសល្យវប្បធម៌ចម្រុះឲ្យបាន ដល់សាធារណជន ពិសេសដល់អ្នកជំនាន់ក្រោយ ដែលជាអ្នកបន្តវេនពីជំនាន់របស់យើង។

អនុលោមតាមស្មារតីខាងលើ ឆ្នាំ២០១៨ នេះរាជរដ្ឋាភិបាលកម្ពុជាបន្តរៀបចំប្រារព្ធ ទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ដោយសម្រេចកំណត់យកប្រធានបទ «អ្វីៗទាំងអស់ ដើម្បីសុខដុមភាពវប្បធម៌ជាតិ» ក្នុងគោលបំណងធ្វើឲ្យប្រជាជន មហាជន ពិសេសយុវជន ទូទាំងប្រទេស៖

- បង្កើននូវការដឹងគុណចំពោះបុព្វការីជន ដែលបានខិតខំប្រឹងប្រែងកសាងសម្បត្តិវប្បធម៌ដ៏សម្បូរបែបប្រកបដោយសក្តានុពលភាព ក្នុងការរួមចំណែកអភិវឌ្ឍសង្គម និងភាពសុខសាន្តរបស់ប្រជាជន និងប្រជាជាតិនៃយើង
- បានយល់ដឹងកាន់តែច្បាស់ពីតម្លៃពិតនៃវប្បធម៌ជាតិ ដែលជាប្រភពមិនចេះរីងស្ងួតក្នុងការបង្កើតការងារ និងកាលានុវត្តភាព ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយប្រសិទ្ធភាពពីធនធានទាំងនោះ
- កាន់តែស្រឡាញ់ និងកាន់តែមានស្មារតីចូលរួមសកម្មថែមទៀត ក្នុងការថែរក្សាការពារវប្បធម៌ចម្រុះនៅកម្ពុជា ដែលជាមូលដ្ឋាននៃសាមគ្គីភាព ឯកភាពជាតិ និងភាពសុខសាន្តរបស់ប្រជាជន ព្រមទាំងសុខដុមភាពនៃវប្បធម៌
- ចេះប្រើប្រាស់សក្តានុពលវប្បធម៌ធ្វើជាមូលដ្ឋានគ្រឹះ ក្នុងការអភិវឌ្ឍសង្គម តាមរយៈការបង្កើតសេវាកម្ម និងផលិតផលវប្បធម៌សម្រាប់គោលដៅពាណិជ្ជកម្ម និងទេសចរណ៍
- ចូលរួមកាន់តែសកម្មក្នុងការផ្ទេរ និងទទួលយកនូវចំណេះជំនាញ បច្ចេកទេសលើវិស័យវប្បធម៌ជាតិ
- ចូលរួមយ៉ាងសកម្មក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងរក្សាទុកឲ្យបានគង់វង្សនូវឯកសារបេតិកភណ្ឌវប្បធម៌គ្រប់ប្រភេទដែលមានក្នុងមូលដ្ឋានរបស់ខ្លួន
- លើកស្ទួយវប្បធម៌ចម្រុះឲ្យទទួលបាននូវវឌ្ឍនភាព ប្រកបដោយនិរន្តរភាព ដើម្បីសុខដុមរស់មិនប្រកាន់និន្នាការ ពណ៌សម្បុរ និងគ្មានការរើសអើង។

អាស្រ័យហេតុនេះ ដើម្បីឲ្យការរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ឆ្នាំ ២០១៨ ក្រោមប្រធានបទ «អ្វីៗទាំងអស់ដើម្បីសុខដុមភាពវប្បធម៌ជាតិ» ប្រព្រឹត្តទៅប្រកបដោយជោគជ័យស្របតាមគោលបំណងខាងលើ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

១- គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី សហគ្រាសរដ្ឋ និងឯកជន ព្រមទាំងគ្រប់លំនៅឋាន ត្រូវលើកទង់ជាតិ ទង់ផ្ទាំង បដាពាក្យស្លោក បិទផ្សាយអាហ្វីសតាមដងផ្លូវសាធារណៈ ទីលានសាធារណៈ អគ្គភាព និងលំនៅឋានរបស់ខ្លួនឲ្យបានគ្រប់ៗគ្នាចាប់ពីថ្ងៃទី១ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨។

២- ក្រសួងព័ត៌មាន ត្រូវរៀបចំកម្មវិធីផ្សព្វផ្សាយពិសេសតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន កាសែត និងទស្សនាវដ្តីនូវខ្លឹមសារនៃទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ព្រមទាំងឯកសារពាក់ព័ន្ធ ដើម្បីបំផុសឲ្យសាធារណជនចូលរួមកាន់តែសកម្មថែមទៀត ក្នុងការថែរក្សាការពារសម្បត្តិវប្បធម៌ លើកស្ទួយសីលធម៌សង្គម ចេះរួមរស់ជាមួយគ្នាដោយមិនប្រកាន់និន្នាការវប្បធម៌ ស្របតាមប្រធានបទ «អ្វីៗទាំងអស់ដើម្បីសុខដុមភាពវប្បធម៌ជាតិ»។

៣ - ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបើកកម្មវិធីប្រកួតប្រជែងក្នុងមជ្ឈដ្ឋានសិស្ស និស្សិត តាមរយៈការបង្កើត «សំណួរ-ចម្លើយ» ដោយផ្តោតទៅលើប្រធានបទ «អ្វីៗទាំងអស់ដើម្បីសុខដុមភាពវប្បធម៌ជាតិ» និងស្របតាមខ្លឹមសារខាងលើ។

៤ - ក្រសួងទេសចរណ៍ ត្រូវធ្វើការផ្សព្វផ្សាយអំពីទេសចរណ៍វប្បធម៌ តាមគ្រប់រូបភាពឲ្យបានទូលំទូលាយ ជាពិសេសក្នុងព្រឹត្តិការណ៍ទេសចរជាតិ និងអន្តរជាតិ សំដៅបង្កើនភាពទាក់ទាញ។

៥ - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវណែនាំដល់គ្រប់ឯកអគ្គរាជទូត អគ្គរដ្ឋទូត អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ឲ្យរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ឆ្នាំ ២០១៤ ។

៦- ក្រសួងធម្មការ និងសាសនា ត្រូវបំផុសចលនាព្រះសង្ឃ និងគ្រប់សាសនិក ឲ្យរៀបចំកម្មវិធីផ្សព្វផ្សាយខ្លឹមសារទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ នៅតាមទីអារាម ព្រះវិហារ មណ្ឌលវិបស្សនា និងទីសក្ការៈផ្សេងៗ ។

៧ - អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ ត្រូវរៀបចំពិធីមីទ្ទិញអបអរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ឆ្នាំ ២០១៤ ឲ្យបានផុលផុស។

៨ - អាជ្ញាធរដែនដី រាជធានី ខេត្ត ត្រូវចូលរួមជួយឧបត្ថម្ភគាំទ្រ និងបង្កលក្ខណៈឲ្យមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរៀបចំពិធីមីទ្ទិញអបអរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៦ ឆ្នាំ ២០១៤ នៅក្នុងដែនដីរបស់ខ្លួន ដោយមានកម្មវិធីសម្តែងសិល្បទស្សនីយភាពជូនសាធារណជនទស្សនាកំសាន្តដោយផ្តោតសំខាន់ទៅលើការផ្សព្វផ្សាយ អប់រំប្រជាជន មហាជន ពិសេសស្រទាប់យុវជន ឲ្យកាន់តែមានស្មារតីមុតមាំថែមទៀត ក្នុងការចូលរួមថែរក្សា ការពារពហុវប្បធម៌ដែលជាមូលដ្ឋានគ្រឹះនៃសាមគ្គីភាព ឯកភាពជាតិ និងគ្មានការរើសអើង ដើម្បីភាពសុខសាន្តរបស់ប្រជាជន ព្រមទាំងសុខដុមភាពនៃវប្បធម៌ៗ ដើម្បីបង្ហាញនូវសុច្ឆន្ទៈប្រកបដោយមនសិការស្នេហាវប្បធម៌ជាតិខ្ពស់ គ្រប់សមាជិក សមាជិកា ដែលចូលរួមក្នុងព្រឹត្តិការណ៍ទិវាវប្បធម៌ជាតិ ៣ មីនា ត្រូវស្លៀកពាក់តាមបែបប្រពៃណីជាតិឲ្យបានគ្រប់ៗគ្នា។

៩ - ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំបែងចែកកងកម្លាំងដើម្បីសហការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ នៅតាមទីកន្លែងប្រារព្ធពិធីអបអរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៦ ឲ្យមានសុវត្ថិភាពខ្ពស់។

១០ - ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវធ្វើជាលេខាធិការដ្ឋានក្នុងការរៀបចំឯកសារឃោសនា ផ្សព្វផ្សាយ បម្រើឲ្យខ្លឹមសារទិវាវប្បធម៌ជាតិ និងត្រូវដឹកនាំគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ក្នុងការរៀបចំទិវាវប្បធម៌ជាតិឲ្យបានព្រមៗគ្នានៅក្នុងអំឡុងដើមខែមីនា ឆ្នាំ ២០១៤ និងត្រូវឲ្យមានការចូលរួមពីគ្រប់ជនជាតិដែលមានទីតាំងនៅលើទឹកដីភូមិសាស្ត្ររបស់ខ្លួន។៚

១១ - គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី រោងចក្រសហគ្រាសរដ្ឋ ព្រមទាំងវិស័យឯកជនទាំងអស់នៅទូទាំងប្រទេស ត្រូវរៀបចំអបអរសាទរទិវាវប្បធម៌ជាតិតាមខ្លឹមសារខាងលើឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ចាប់ពីពេលទទួលបានខ្លឹមសារនៃសារាចរណែនាំនេះ សំដៅអនុវត្តឲ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលអាណត្តិទី ៥។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អាជ្ញាធរជាតិ
- សាលារាជធានី និងខេត្ត
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ ស.ណ.ន

## សេចក្តីណែនាំ
## ស្តីពី
## តួនាទី ភារកិច្ច និងរបៀបរបបការងារ សម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

ដើម្បីគាំទ្រ និងរួមចំណែកជំរុញការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចបង្កើតក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ក្នុងគោលបំណងដើម្បីឲ្យកម្មវិធីនយោបាយខាងលើនេះបានអនុវត្តប្រកបដោយប្រសិទ្ធភាព នៅគ្រប់មូលដ្ឋានទូទាំងប្រទេស។

ដើម្បីជានាឲ្យក្រុមការងារខាងលើនេះ ងាយស្រួលក្នុងការធ្វើសកម្មភាពទទួលបានលទ្ធផលល្អប្រសើរ រាជរដ្ឋាភិបាលកំណត់អំពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារដែលមានខ្លឹមសារដូចខាងក្រោម៖

### I. អំពីតួនាទី ភារកិច្ច

ក្នុងការបំពេញបេសកកម្មនៅមូលដ្ឋាន ក្រុមការងារមានតួនាទីលើកកម្ពស់កិច្ចសហការ សម្របសម្រួលក្នុងការដោះស្រាយបញ្ហានានា ដើម្បីបំរើផលប្រយោជន៍ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។ ក្រុមការងារពុំមានតួនាទី ឬសិទ្ធិសម្រេចកិច្ចការជំនួសក្រសួង ស្ថាប័ននានាឡើយ។ រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ននិមួយៗនៅតែមានតួនាទី និងការទទួលខុសត្រូវស្របតាមគោលការណ៍ច្បាប់ដដែល។ ទន្ទឹមនេះក្រុមការងារក៏ពុំមានតួនាទីចាត់ចែងកិច្ចការជំនួសរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចនានាឡើយ។ ក្រុមការងារមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

១. ផ្សារភ្ជាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយឲ្យបានទូលំទូលាយ នូវកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយឃុំ ភូមិមានសុវត្ថិភាព កម្មវិធីគោលនយោបាយតាមវិស័យ ក៏ដូចជាសភាពការណ៍រួមរបស់ប្រទេសជាតិ ដោយផ្សារភ្ជាប់ជាមួយសភាពការណ៍នៅមូលដ្ឋាន។

២. លើកកម្ពស់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការត្រួតពិនិត្យ តាមដាន និងគាំទ្រការអនុវត្តកម្មវិធី គម្រោង និងផែនការសកម្មភាពនានានៅតាមមូលដ្ឋាន។

៣. សហការជំរុញ និងលើកកម្ពស់គណនេយ្យភាពរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋានឲ្យមានប្រសិទ្ធភាព។

៤. សហការរៀបចំវេទិកាសាធារណៈនៅតាមមូលដ្ឋាន ដើម្បីស្តាប់សំណូមពរ និងសំណើរបស់ប្រជាពលរដ្ឋ ព្រមទាំងយកចិត្តទុកដាក់ដោះស្រាយនូវរាល់សំណូមពរ និងសំណើទាំងនោះ ដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្នុងករណីមិនអាចដោះស្រាយបាន ក្រុមការងារត្រូវបូកសរុប និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។ វេទិកាសាធារណៈនេះគប្បីយកចិត្តទុកដាក់អំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

៥. សហការដោះស្រាយបញ្ហាប្រឈម និងការលំបាកនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

៦. កៀគរធនធានពីប្រភពនានា ដើម្បីចូលរួមក្នុងការដោះស្រាយជីវភាពប្រជាពលរដ្ឋ ក៏ដូចជាការអភិវឌ្ឍមូលដ្ឋាន។

**II. អំពីការរៀបចំក្រុមការងារ របៀបរបបការងារ និងការចាត់តាំងអនុវត្ត**

**ក. អំពីការរៀបចំក្រុមការងារថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់**

១. រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ននានាត្រូវចាត់បញ្ជូនមន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬថ្នាក់ប្រហាក់ប្រហែល ដើម្បីបំពេញរចនាសម្ព័ន្ធក្រុមការងារថ្នាក់ជាតិដែលបានសម្រេចរួចហើយ។

២. ក្រុមការងារថ្នាក់ជាតិ និងគណៈអភិបាលរាជធានី ខេត្ត ត្រូវសហការរៀបចំបែងចែក និងបំពេញបន្ថែមសមាសភាព ដើម្បីចុះបេសកកម្មតាមក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

**ខ. អំពីរបៀបរបបការងារ និងការចាត់តាំងអនុវត្ត**

១. បន្ទាប់ពីបានរៀបចំក្រុមការងារដូចមានចែងក្នុងចំណុច "ក" ខាងលើរួចរាល់ហើយ ក្រុមការងារតាមថ្នាក់នីមួយៗត្រូវជួបប្រជុំស្តាប់របាយការណ៍ពីថ្នាក់រដ្ឋបាលនោះ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាព និងកម្មវិធីការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។ ទន្ទឹមនេះក្រុមការងារត្រូវជួបប្រាស្រ័យដោយផ្ទាល់ជាមួយសហគមន៍ និងប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព និងកម្មវិធីការងាររបស់ខ្លួនជាប្រចាំ។

២. ក្រុមការងារគ្រប់ថ្នាក់ត្រូវមានរបបប្រជុំ និងរបាយការណ៍យ៉ាងតិចមួយត្រីមាសម្តង និងអាចកោះប្រជុំ និងធ្វើរបាយការណ៍ តាមការចាំបាច់។ សមាជិកក្រុមការងារទាំងអស់ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារ។ សមាជិកក្រុមការងារម្នាក់ៗ ត្រូវបែងចែកពេលវេលាឲ្យបានសមស្របសម្រាប់បំពេញការងារក្នុងក្រសួង ស្ថាប័នរបស់ខ្លួន និងពេលវេលាសម្រាប់ចុះតាមមូលដ្ឋានដែលខ្លួនទទួលខុសត្រូវ។

ក្រុមការងារថ្នាក់ជាតិត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល រៀងរាល់ត្រីមាស។ ក្នុងករណីចាំបាច់ ក្រុមការងារអាចធ្វើសេចក្តីរាយការណ៍ និងសុំយោបល់ដឹកនាំដោយផ្ទាល់ពីនាយករដ្ឋមន្ត្រី។

៣. ក្នុងការដោះស្រាយបញ្ហានានានៅមូលដ្ឋាន ក្រុមការងារត្រូវផ្អែកលើច្បាប់ និងលិខិតបទដ្ឋានជាធរមាន ហើយប្រធានក្រុមការងារត្រូវចាត់ឲ្យសមាជិកក្នុងក្រុមការងារ និងអាជ្ញាធរពាក់ព័ន្ធធ្វើការសម្របសម្រួលក្នុងក្រសួង ស្ថាប័នសាមី និងអាជ្ញាធរពាក់ព័ន្ធទាំងនោះ ដើម្បីសហការដោះស្រាយ។

៤. រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ធ្វើជាសេនាធិការជូននាយករដ្ឋមន្ត្រី ដើម្បីសម្របសម្រួលការបំពេញបេសកកម្មនៃក្រុមការងារ។ របាយការណ៍ទាំងឡាយត្រូវចម្លងជូនឯកឧត្តម **ស ខេង** មួយច្បាប់ ដើម្បីងាយស្រួលក្នុងការតាមដាន និងសម្របសម្រួល។

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចាត់តាំងអនុវត្តឲ្យមានប្រសិទ្ធភាពនូវសេចក្តីណែនាំនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណង ដូចខាងក្រោម÷

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំមុខងារនិងភារកិច្ចរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យរតនាគារនិងវិស័យគណនេយ្យសាធារណៈ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់អង្គភាពនៃអគ្គនាយកដ្ឋានរតនាគារជាតិ ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋាន ដែលរួមមានជាអាទិ៍ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី២

## អំពីបេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានរតនាគារជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ÷

- ជាបេឡាករនិងជាគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋនិងគណនីពិសេសនៃរតនាគារ
- រៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យសាធារណៈ
- កាន់កាប់និងតាមដានការអនុវត្តគណនេយ្យទូទៅនិងមជ្ឈការគណនី
- ធានាតុល្យភាពទូទៅនៃគណនី
- តម្រង់ទិសនិងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុនិងបំណុលសាធារណៈ
- សហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

**ប្រការ៥.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងបេឡាថវិកាថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន និងថវិកាស្វយ័ត
- គ្រប់គ្រងគណនីរបស់ក្រសួង ស្ថាប័នថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន គណនីប្រាក់បញ្ញើឯកជន គណនីក្រៅថវិកា និងគណនីពិសេសរបស់រតនាគារ
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋ មូលបត្ររដ្ឋ និងសញ្ញាប័ណ្ណរដ្ឋ
- ធ្វើតុល្យភាពសាច់ប្រាក់ និងគ្រប់គ្រងចំណូល ចំណាយថវិកាជាតិ
- រួមចំណែកក្នុងការតម្រង់ទិសការអនុវត្តគោលនយោបាយរូបិយវត្ថុ
- តម្រង់ទិសនិងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុនិងបំណុលសាធារណៈ

- កាន់កាប់និងតាមដានការអនុវត្តគណនេយ្យទូទៅនិងមជ្ឈការគណនី
- រៀបចំគោលការណ៍ និងបិទបញ្ជីគណនេយ្យសាធារណៈ
- ធានាតុល្យភាពទូទៅនៃគណនី
- ផ្តល់សេវាដល់គ្រប់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល និងរដ្ឋបាលថ្នាក់មូលដ្ឋាន លើការទូទាត់ ការចំណាយផ្សេងៗ ការបើកបៀវត្សរ៍ និងការប្រមូលចំណូល ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

**ប្រការ៦.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក. ថ្នាក់កណ្តាល**

១. នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក

២. នាយកដ្ឋានចំណូលនិងចំណាយថវិកា

៣. នាយកដ្ឋានគណនេយ្យ

៤. នាយកដ្ឋានគ្រប់គ្រងបេឡានិងបំណុល

៥. នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ

៦. នាយកដ្ឋានព័ត៌មានវិទ្យា

៧. អធិការកិច្ចរតនាគារ ថ្នាក់ស្មើនាយកដ្ឋាន

៨. អង្គភាពគ្រប់គ្រងសាច់ប្រាក់

៩. លេខាធិការដ្ឋាន។

**ខ. ថ្នាក់មូលដ្ឋាន**

នៅថ្នាក់មូលដ្ឋាន មានរតនាគាររាជធានី ខេត្ត ដែលមានការិយាល័យក្រោមឱវាទ ចំនួន ៣ ដូចខាងក្រោម ÷

១.ការិយាល័យរដ្ឋបាលនិងបុគ្គលិក

២.ការិយាល័យគណនេយ្យ

៣.ការិយាល័យឃ្លាំងបេឡា។

**ប្រការ៧.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

អធិការកិច្ចរតនាគារ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន ដែលអមដោយអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ។

អង្គភាពគ្រប់គ្រងសាច់ប្រាក់ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ដែលអមដោយអនុប្រធានមួយចំនួន មានឋានៈស្មើប្រធានការិយាល័យ ជាជំនួយការ។

លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានរតនាគារជាតិ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ដែលអមដោយអនុប្រធានមួយចំនួន មានឋានៈស្មើប្រធានការិយាល័យ ជាជំនួយការ ។

រតនាគាររាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអម ដោយអនុប្រធានមួយចំនួន មានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ ។

ការិយាល័យនីមួយៗនៅថ្នាក់កណ្តាល ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

ការិយាល័យនីមួយៗនៅថ្នាក់មូលដ្ឋាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធានការិយាល័យនៅថ្នាក់កណ្តាល ដែលអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គការលេខរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៣

## នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក

**ប្រការ៨.-**

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងាររដ្ឋបាល និងបុគ្គលិក ដោយមានភារកិច្ចដូចតទៅ ÷

- រៀបចំនិងតាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង
- បញ្ជូនឯកសារ ទទួលលិខិតចេញ ចូល និងរៀបចំចងក្រងទុកដាក់ឯកសារ
- ពិនិត្យទិដ្ឋាការបេសកកម្មចេញ ចូល និងតាមដានគ្រប់គ្រងប្រាក់បេសកកម្ម
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់
- បញ្ជិកាតាមដានប្រាក់ជំពូក គណនី អនុគណនី សម្រាប់កិច្ចដំណើរការរដ្ឋបាល
- គ្រប់គ្រង បែងចែក និងបើកផ្តល់ប្រាក់លាភការ ប្រាក់បៀវត្សរ៍ និងសម្ភារៈការិយាល័យ
- គ្រប់គ្រងមន្ត្រីរាជការ កម្មករជាប់កិច្ចសន្យា
- រៀបចំរចនាសម្ព័ន្ធចាត់តាំង អង្គការលេខ។

**ប្រការ៩.-**

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម ÷

១. ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ

២. ការិយាល័យបុគ្គលិក

៣. ការិយាល័យទំនាក់ទំនងនិងពិធីការ។

**ប្រការ១០.-**

ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ មានភារកិច្ច ដូចតទៅ÷

- រៀបចំនិងតាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង
- បញ្ជូនសារ ទទួលលិខិតចេញ ចូល
- រៀបចំចងក្រងឯកសារ

- ពិនិត្យទិដ្ឋាការបេសកកម្មចេញ ចូល
- គ្រប់គ្រងអចលនទ្រព្យនិងចលនទ្រព្យ
- គ្រប់គ្រងការងារសន្តិសុខ សណ្តាប់ធ្នាប់
- បញ្ជិកាតាមដានប្រាក់ជំពូក គណនី អនុគណនីសម្រាប់កិច្ចដំណើរការរដ្ឋបាល
- តាមដាននិងគ្រប់គ្រងប្រាក់កម្រៃរតនាគារ
- គ្រប់គ្រងនិងបែងចែកប្រាក់កម្រៃរតនាគារ
- គ្រប់គ្រងនិងបែងចែកប្រាក់បៀវត្សរ៍និងសម្ភារៈការិយាល័យ និងគ្រប់គ្រងប្រាក់បេឡា
- រៀបចំគម្រោងចំណូល ចំណាយថវិការបស់អគ្គនាយកដ្ឋានរតនាគារជាតិប្រចាំឆ្នាំ។

**ប្រការ១១.-**

ការិយាល័យបុគ្គលិក មានភារកិច្ច ដូចតទៅ÷

- គ្រប់គ្រងមន្ត្រីរាជការ កម្មករជាប់កិច្ចសន្យា
- រៀបចំក្របខណ្ឌមន្ត្រីរាជការ
- រៀបចំកាំប្រាក់មន្ត្រីរាជការ
- រៀបចំតារាងទូទាត់ប្រាក់បៀវត្សរ៍មន្ត្រីរាជការ
- លើកសំណើលើការពិនិត្យ វាយតម្លៃ លើកសរសើរ តែងតាំង និងដាក់ពិន័យមន្ត្រីរាជការ
- តាមដានបញ្ជីវត្តមាន អវត្តមានមន្ត្រីរាជការ
- រៀបចំរចនាសម្ព័ន្ធចាត់តាំង អង្គការលេខ
- រៀបចំលិខិតឧទ្ទេសនាមនិងលិខិតបញ្ជាបេសកកម្មផ្សេងៗ
- រៀបចំចាត់តាំងមន្ត្រីរាជការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល បុណ្យជាតិ អន្តរជាតិ និងរាល់សកម្មភាពនានារបស់រដ្ឋ
- រៀបចំលិខិតឈប់សម្រាកនានារបស់មន្ត្រីរាជការ។

**ប្រការ១២.-**

ការិយាល័យទំនាក់ទំនងនិងពិធីការ មានភារកិច្ច ដូចតទៅ÷

- ទំនាក់ទំនងនិងសម្របសម្រួលជាមួយនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ទំនាក់ទំនងនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័ននានា
- រៀបចំពិធីនិងការប្រជុំនានារបស់អគ្គនាយកដ្ឋានរតនាគារជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំបដាពាក្យស្លោក តុបតែងលម្អអគ្គនាយកដ្ឋានរតនាគារជាតិ នៅពេលមានពិធីបុណ្យជាតិ អន្តរជាតិ
- រៀបចំទទួលភ្ញៀវជាតិ អន្តរជាតិ
- រៀបចំពីធីការរាល់ការចុះហត្ថលេខាលើពិធីសានានា
- ថែរក្សា តុបតែងសាលប្រជុំ និងបន្ទប់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានរតនាគារជាតិ។

## ជំពូកទី៤
## នាយកដ្ឋានចំណូលនិងចំណាយថវិកា

**ប្រការ១៣.-**

នាយកដ្ឋានចំណូលនិងចំណាយថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារចំណូលនិងចំណាយថវិកា ដោយមានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រងនិងតាមដានចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ
- ទទួលចំណូលប្រាក់ជំពាក់ ប្រាក់បំណុលរបស់រដ្ឋ និងប្រាក់វិវាទ
- បញ្ជិកាប្រាក់ពន្ធជាបន្ទុករបស់រដ្ឋ ប្រាក់ជំពាក់ ចំណូលថវិកាថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- គ្រប់គ្រងគណនីរដ្ឋទេយ្យចំណូល គណនីចំណូលបណ្តោះអាសន្នរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ
- ពិនិត្យបញ្ជាក់អាណត្តិបើកប្រាក់និងលិខិតយុត្តិការភ្ជាប់តាមអាណត្តិបើកប្រាក់
- ពិនិត្យឥណទានទំនេររបស់ក្រសួង ស្ថាប័ន
- បញ្ជិកាតាមដានប្រាក់បុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន និងចំណាយតាមកិច្ចសន្យា
- ចុះកិច្ចបញ្ជិកាតាមដានលម្អិតចំណូល ចំណាយថវិកាថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ជាប្រាក់រៀលនិងប្រាក់រូបិយប័ណ្ណបរទេស
- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស និងឆ្នាំ។

**ប្រការ១៤.-**

នាយកដ្ឋានចំណូលនិងចំណាយថវិកា មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម ÷

១. ការិយាល័យចំណាយថវិកាទី១និងសរុប

២. ការិយាល័យចំណាយថវិកាទី២

៣. ការិយាល័យចំណាយថវិការូបិយប័ណ្ណបរទេស

៤. ការិយាល័យចំណូលថវិកា។

**ប្រការ១៥.-**

ការិយាល័យចំណាយថវិកាទី១និងសរុប មានភារកិច្ចដូចតទៅ÷

- ពិនិត្យឥណទានទំនេររបស់ក្រសួង ស្ថាប័ន
- ពិនិត្យបញ្ជាក់អាណត្តិបើកប្រាក់
- ពិនិត្យលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់
- រៀបចំលេខនានិងអាណត្តិបើកប្រាក់ផ្នែកខាងក្រោម បញ្ជូនទៅនាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់អាណត្តិបើកប្រាក់ជាប្រាក់រៀល
- បញ្ជិកាតាមដានឥណទានបុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន និងចំណាយតាមកិច្ចសន្យា
- បញ្ជិកាតាមដានលម្អិតចំណាយថវិកាថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- ធ្វើការផ្ទៀងផ្ទាត់របាយការណ៍ប្រចាំខែ ឆ្នាំ ជាមួយតារាងតុល្យភាពគណនី និងជាមួយសាមីក្រសួងចំណាយ

- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ។

**ប្រការ១៦.-**

ការិយាល័យចំណាយថវិកាទី២ មានភារកិច្ចដូចតទៅ÷

- ពិនិត្យឥណទានទំនេររបស់ក្រសួង ស្ថាប័ន
- ពិនិត្យបញ្ជាក់អាណត្តិបើកប្រាក់
- ពិនិត្យលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់
- រៀបចំលេខនា និងអាណត្តិបើកប្រាក់ផ្នែកខាងក្រោម បញ្ជូនទៅនាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់អាណត្តិបើកប្រាក់ជាប្រាក់រៀល
- បញ្ជិកាតាមដានឥណទានបុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន និងចំណាយតាមកិច្ចសន្យា
- បញ្ជិកាតាមដានលម្អិតចំណាយថវិកាថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- ធ្វើការផ្ទៀងផ្ទាត់របាយការណ៍ប្រចាំខែ ឆ្នាំ ជាមួយតារាងតុល្យភាពគណនីនិងជាមួយសាមីក្រសួងចំណាយ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ។

**ប្រការ១៧.-**

ការិយាល័យចំណាយថវិការូបិយប័ណ្ណបរទេស មានភារកិច្ចដូចតទៅ÷

- ពិនិត្យបញ្ជាក់អាណត្តិបើកប្រាក់ជារូបិយប័ណ្ណបរទេស
- ពិនិត្យលិខិតយុត្តិការតាមដានអាណត្តិបើកប្រាក់ជារូបិយប័ណ្ណបរទេស
- រៀបចំលេខនា និងអាណត្តិបើកប្រាក់ផ្នែកខាងក្រោម បញ្ជូនទៅនាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់អាណត្តិបើកប្រាក់ជារូបិយប័ណ្ណបរទេស
- បញ្ជិកាតាមដានឥណទានបុរេប្រទាន រដ្ឋទេយ្យបុរេប្រទាន និងចំណាយតាមកិច្ចសន្យាជារូបិយប័ណ្ណបរទេស
- ចុះកិច្ចបញ្ជិកាតាមដានលម្អិតចំណាយថវិកាថ្នាក់កណ្តាលជារូបិយប័ណ្ណបរទេស
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ។

**ប្រការ១៨.-**

ការិយាល័យចំណូលថវិកា មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងនិងតាមដានចំណូលមិនមែនសារពើពន្ធ
- ទទួលប្រាក់ពិន័យ ប្រាក់ពន្ធ ប្រាក់បំណុលរបស់រដ្ឋ និងប្រាក់វិវាទ
- បញ្ជិកាប្រាក់ពន្ធជាបន្ទុករបស់រដ្ឋ និងប្រាក់ពិន័យ
- ចុះកិច្ចបញ្ជិកាតាមដានលម្អិតចំណូលថវិកាថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- គ្រប់គ្រងគណនីរដ្ឋទេយ្យចំណូល គណនីចំណូលបណ្តោះអាសន្នរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ
- ធ្វើការផ្ទៀងផ្ទាត់របាយការណ៍ប្រចាំខែ ឆ្នាំ ជាមួយក្រសួង ស្ថាប័ន

- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆ្នាំ។

## ជំពូកទី៥

## នាយកដ្ឋានគណនេយ្យ

**ប្រការ១៩.-**

នាយកដ្ឋានគណនេយ្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគណនេយ្យ ដោយមានភារកិច្ចដូចតទៅ ÷

- រៀបចំគោលការណ៍និងបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- ទទួលពិនិត្យ និងប្រមូលផ្តុំសលាកប័ត្រលេខនា និងសក្ខីប័ត្រគណនេយ្យ
- រៀបចំឯកសារទាក់ទងនឹងការផ្ទេរ និងទទួលសាច់ប្រាក់រវាងរតនាគារថ្នាក់កណ្តាល និងរតនាគារថ្នាក់មូលដ្ឋាន
- រៀបចំឯកសារទាក់ទងនឹងការផ្ទេរប្រតិបត្តិការរវាងរតនាគារថ្នាក់កណ្តាល និងរតនាគារថ្នាក់មូលដ្ឋាន
- គ្រប់គ្រងគណនីប្រាក់បញ្ញើរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងគ្រឹះស្ថានសាធារណៈ
- គ្រប់គ្រងគណនីប្រាក់បញ្ញើផ្សេងៗ
- គ្រប់គ្រងគណនីធនាគារជាប្រាក់រៀលនិងប្រាក់រូបិយប័ណ្ណបរទេស គណនីជំនួយទ្រទ្រង់ថវិកាជាតិ និងគណនីពិសេសផ្សេងៗទៀត
- ធ្វើការទូទាត់និងបើកផ្តល់ចំណាយ
- រៀបចំតារាងតុល្យភាពគណនីនិងរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំខែ ឆ្នាំ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ផ្សេងៗ តាមតម្រូវការចាំបាច់។

**ប្រការ២០.-**

នាយកដ្ឋានគណនេយ្យ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យគណនេយ្យទី១និងសរុប

២. ការិយាល័យគណនេយ្យទី២

៣. ការិយាល័យគណនេយ្យទី៣

៤. ការិយាល័យប្រាក់បញ្ញើ។

**ប្រការ២១.-**

ការិយាល័យគណនេយ្យទី១និងសរុប មានភារកិច្ចដូចតទៅ÷

- រៀបចំគោលការណ៍ និងបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈដែលពាក់ព័ន្ធនឹងថវិការដ្ឋ
- ប្រមូលលេខនាប្រតិបត្តិការប្រចាំថ្ងៃរបស់ថវិការដ្ឋនៅថ្នាក់កណ្តាល
- ប្រមូលតារាងសរុបវិភាគគណនីប្រចាំថ្ងៃ ធ្វើការបូកសរុប និងផ្ទៀងផ្ទាត់
- គ្រប់គ្រងគណនីប្រាក់បុរេប្រទានចំណាយចរន្ត
- គ្រប់គ្រងគណនីចម្លង និងគណនីរង់ចាំផ្សេងៗ

- គ្រប់គ្រងគណនីអ្នកផ្គត់ផ្គង់និងគណនីសោហ៊ុយបេសកកម្មនិងសោហ៊ុយផ្សេងៗដែលត្រូវសងរបស់ក្រសួង- ស្ថាប័នមួយចំនួន
- រៀបចំបែបបទទូទាត់ជូនអគ្គតាហក
- ពិនិត្យបញ្ជីវិភាគគណនីទំនាក់ទំនង ប្រកាសផ្ទេរឥណទាន រវាងរតនាគារថ្នាក់កណ្តាល និងរតនាគារថ្នាក់មូលដ្ឋាន
- ពិនិត្យនិងតាមដានគណនីនិយ័តកម្មសាច់ប្រាក់ដែលបានទទួលនិងបានផ្ទេររវាងរតនាគារថ្នាក់កណ្តាលនិងរតនាគារថ្នាក់មូលដ្ឋាន
- ពិនិត្យតារាងប្រៀបធៀបគណនីទំនាក់ទំនងរវាងរតនាគារថ្នាក់កណ្តាលនិងរតនាគារថ្នាក់មូលដ្ឋាន
- រៀបចំតារាងតុល្យភាពគណនីថវិការដ្ឋ នៅរាជធានី ខេត្ត ប្រចាំខែ ឆ្នាំ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុថវិការដ្ឋ នៅរាជធានី ខេត្ត ប្រចាំខែ ឆ្នាំ
- រៀបចំតារាងតុល្យភាពគណនីថវិការដ្ឋ ប្រចាំខែ ឆ្នាំ នៅរតនាគារថ្នាក់កណ្តាល
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុថវិការដ្ឋ ប្រចាំខែ ឆ្នាំ នៅរតនាគារថ្នាក់កណ្តាល
- រៀបចំតារាងតុល្យភាពគណនីសរុបទូទាំងប្រទេសនៃថវិការដ្ឋ ប្រចាំខែ ឆ្នាំ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសរុបទូទាំងប្រទេសនៃថវិការដ្ឋ ប្រចាំខែ ឆ្នាំ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ផ្សេងៗ តាមតម្រូវការចាំបាច់។

**ប្រការ២២.-**

កាវិយាល័យគណនេយ្យទី២ មានភារកិច្ច ដូចតទៅ÷

- រៀបចំគោលការណ៍ និងបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈដែលពាក់ព័ន្ធនឹងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រងគណនីអ្នកផ្គត់ផ្គង់ និងគណនីសោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗ ត្រូវសង របស់ក្រសួង-ស្ថាប័នមួយចំនួន
- រៀបចំបែបបទទូទាត់ជូនអគ្គតាហក
- គ្រប់គ្រងគណនីប្រាក់បុរេប្រទានសម្រាប់វិនិយោគ
- រៀបចំតារាងតុល្យភាពគណនីសរុបនៃថវិការបស់រាជធានី ខេត្ត ប្រចាំខែ ឆ្នាំ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសរុបនៃថវិការបស់រាជធានី ខេត្ត ប្រចាំខែ ឆ្នាំ
- រៀបចំតារាងតុល្យភាពគណនីសរុបនៃថវិការបស់ក្រុង ស្រុក ខណ្ឌ ប្រចាំខែ ឆ្នាំ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសរុបនៃថវិការបស់ក្រុង ស្រុក ខណ្ឌ ប្រចាំខែ ឆ្នាំ
- រៀបចំតារាងតុល្យភាពគណនីសរុបនៃថវិការបស់ឃុំ សង្កាត់ ប្រចាំខែ ឆ្នាំ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសរុបនៃថវិការបស់ឃុំ សង្កាត់ ប្រចាំខែ ឆ្នាំ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ផ្សេងៗ តាមតម្រូវការចាំបាច់។

**ប្រការ២៣.-**

ការិយាល័យគណនេយ្យទី៣ មានភារកិច្ចដូចតទៅ÷

- រៀបចំគោលការណ៍ និងបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈដែលពាក់ព័ន្ធនឹងចរិការបស់គ្រឹះស្ថានសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល
- ពិនិត្យនិងតាមដានកិច្ចបញ្ជិកាគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈ
- រៀបចំបញ្ជាផ្ទេរសាច់ប្រាក់ទៅរតនាគារថ្នាក់មូលដ្ឋាន
- រៀបចំសំណើផ្ទេរសាច់ប្រាក់រវាងគណនីធនាគារជាតិនៃកម្ពុជា
- គ្រប់គ្រងគណនីធនាគារជាប្រាក់រៀលនិងគណនីមូលប្បទានប័ត្រដែលបានបោះផ្សាយ ជាប្រាក់រៀលនិងដុល្លារ
- គ្រប់គ្រងគណនីចំណាយរង់ចាំធ្វើនិយ័តកម្មប្រាក់ដើម ការប្រាក់ខ្ចី និងការប្រាក់បំណុលរតនាគារ
- គ្រប់គ្រងគណនីធនាគារជារូបិយប័ណ្ណបរទេសនិងប្រាក់បញ្ញើជំនួយ
- គ្រប់គ្រងគណនីអ្នកផ្គត់ផ្គង់និងគណនីសោហ៊ុយបេសកកម្មនិងសោហ៊ុយផ្សេងៗ ត្រូវសង ជារូបិយប័ណ្ណបរទេសនិងប្រាក់រៀលរបស់ក្រសួង-ស្ថាប័នមួយចំនួន
- កាន់គណនីបុរេប្រទានចរន្ត និងវិនិយោគ ជារូបិយប័ណ្ណបរទេស
- រៀបចំបែបបទទូទាត់ជូនអត្ថគាហក ជាប្រាក់រៀលនិងដុល្លារ
- កត់ត្រាសមាហរណកម្មបំណុលប្រាក់ខ្ចីនិងប្រាក់ឱ្យខ្ចី
- គ្រប់គ្រងគណនីចម្លងនិងគណនីរង់ចាំផ្សេងៗ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ចរិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ផ្សេងៗ តាមតម្រូវការចាំបាច់។

**ប្រការ២៤.-**

ការិយាល័យប្រាក់បញ្ញើ មានភារកិច្ច ដូចតទៅ÷

- រៀបចំគោលការណ៍និងបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈដែលពាក់ព័ន្ធនឹងការគ្រប់គ្រងគណនីប្រាក់បញ្ញើរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រងគណនីប្រាក់បញ្ញើរបស់ភ្នាក់ងារបើកផ្តល់
- គ្រប់គ្រងគណនីរដ្ឋទេយ្យករបុរេប្រទាន ផ្អែកតាមចរិកាកម្មវិធីនិងមិនមែនកម្មវិធី
- គ្រប់គ្រងគណនីប្រាក់បញ្ញើរបស់ក្រុមហ៊ុនឯកជន
- គ្រប់គ្រងគណនីប្រាក់បញ្ញើរបស់អង្គភាពចំណុះក្រសួង
- គ្រប់គ្រងគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈ
- គ្រប់គ្រងគណនីមូលនិធិឃុំ សង្កាត់
- គ្រប់គ្រងគណនីមូលនិធិក្រុង ស្រុក
- គ្រប់គ្រងគណនីប្រាក់បញ្ញើចរិកាឧបសម្ព័ន្ធ
- គ្រប់គ្រងគណនីប្រាក់បញ្ញើអង្គការជាតិនិងអន្តរជាតិ
- គ្រប់គ្រងគណនីចម្លង និងគណនីរង់ចាំផ្សេងៗ
- គ្រប់គ្រងគណនីអ្នកផ្គត់ផ្គង់និងគណនីសោហ៊ុយបេសកកម្មនិងសោហ៊ុយផ្សេងៗ ត្រូវសង ជាប្រាក់រៀលរបស់ក្រសួង-ស្ថាប័នមួយចំនួន
- រៀបចំបែបបទទូទាត់ជូនអត្ថគាហក ជាប្រាក់រៀល

- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ផ្សេងៗ តាមតម្រូវការចាំបាច់។

**ជំពូកទី៦**

**នាយកដ្ឋានគ្រប់គ្រងបេឡានិងបំណុល**

**ប្រការ២៥.-**

នាយកដ្ឋានគ្រប់គ្រងបេឡានិងបំណុល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងគណនេយ្យនិងបំណុល ដោយមានភារកិច្ចដូចតទៅ ÷

- ធ្វើប្រតិបត្តិការចំណូល ចំណាយសាច់ប្រាក់
- ប្រគល់ ទទួលសាច់ប្រាក់និយ័តកម្មរវាងថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- ធ្វើការផ្ទៀងផ្ទាត់តួលេខក្នុងឯកសារនៃកិច្ចប្រតិបត្តិការជាមួយនឹងសាច់ប្រាក់ជាក់ស្តែងដែលមានក្នុងឃ្លាំងបេឡា ប្រចាំថ្ងៃ
- ទទួលនិងថែរក្សាមូលបត្ររដ្ឋ សញ្ញាប័ណ្ណរដ្ឋ
- គ្រប់គ្រង លក់ និងសងបំណុលមូលបត្ររដ្ឋ
- គ្រប់គ្រងបំណុលប័ណ្ណរតនាគារ
- បញ្ជិកាបំណុល
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស ឆ្នាំ។

**ប្រការ២៦.-**

នាយកដ្ឋានគ្រប់គ្រងបេឡានិងបំណុល មានការិយាល័យក្រោមឱវាទ ចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យចំណូលសាច់ប្រាក់

២. ការិយាល័យចំណាយសាច់ប្រាក់

៣. ការិយាល័យគ្រប់គ្រងបំណុល ផែនការ និងសរុប។

**ប្រការ២៧.-**

ការិយាល័យចំណូលសាច់ប្រាក់ មានភារកិច្ចដូចតទៅ÷

- ធ្វើប្រតិបត្តិការចំណូលសាច់ប្រាក់
- ពិនិត្យលើសលាកប័ត្របង់ប្រាក់
- រៀបចំប័ណ្ណបង់ប្រាក់
- រាប់សាច់ប្រាក់ ធ្វើតារាងបែងចែកសាច់ប្រាក់ និងចងសាច់ប្រាក់រួចបញ្ចូលឃ្លាំងបេឡា
- ទទួលសាច់ប្រាក់និយ័តកម្មរវាងរតនាគារថ្នាក់កណ្តាលនិងរតនាគារថ្នាក់មូលដ្ឋាន
- ដកមូលនិធិពីធនាគារជាតិនៃកម្ពុជា
- រៀបចំសលាកប័ត្រលេខនាចំណូលសាច់ប្រាក់។

**ប្រការ២៨.-**

ការិយាល័យចំណាយសាច់ប្រាក់ មានភារកិច្ចដូចតទៅ÷

- ធ្វើប្រតិបត្តិការចំណាយសាច់ប្រាក់

- រៀបចំប័ណ្ណចំណាយនិងធ្វើតារាងបែងចែកប្រភេទសាច់ប្រាក់
- បញ្ចេញសាច់ប្រាក់ពីក្នុងឃ្លាំងបេឡាដែលត្រូវចំណាយ
- រៀបចំសលាកប័ត្រចំណាយសាច់ប្រាក់
- ប្រគល់-ទទួលសាច់ប្រាក់និយ័តកម្មរវាងរតនាគារថ្នាក់កណ្តាលនិងរតនាគារថ្នាក់មូលដ្ឋាន។

**ប្រការ២៩.-**

កាវិយាល័យគ្រប់គ្រងបំណុល ផែនការ និងសរុប មានភារកិច្ចដូចតទៅ÷

- កសាងផែនការតុល្យភាពសាច់ប្រាក់
- ទទួលនិងថែរក្សាមូលបត្ររដ្ឋ-សញ្ញាប័ណ្ណរដ្ឋ
- គ្រប់គ្រង លក់ និងសងបំណុលមូលបត្ររដ្ឋ
- គ្រប់គ្រងបំណុលប័ណ្ណរតនាគារ
- បញ្ជិកាចំណូល-ចំណាយនៃកិច្ចប្រតិបត្តិការលក់មូលបត្ររដ្ឋ
- បញ្ជិកាបំណុល
- គ្រប់គ្រងសៀវភៅបញ្ជីបេឡា
- ធ្វើរបាយការណ៍ចំណូល-ចំណាយប្រចាំថ្ងៃ-ខែ-ឆ្នាំ
- ធ្វើការបូកសរុប ផ្ទៀងផ្ទាត់ឯកសារការងារនៃកិច្ចប្រតិបត្តិការចំណូល ចំណាយ ដែលមានក្នុងឃ្លាំងបេឡាប្រចាំថ្ងៃ។

## ជំពូកទី៧

## នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ

**ប្រការ៣០.-**

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ ដោយមានភារកិច្ចដូចតទៅ ÷

- ពិនិត្យតាមដានកិច្ចដំណើរការរបស់រតនាគារថ្នាក់មូលដ្ឋាន
- ពិនិត្យការផ្ទេរមូលនិធិពីថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋាន និងពីថ្នាក់មូលដ្ឋានមកថ្នាក់កណ្តាល
- ពិនិត្យតុល្យភាពសាច់ប្រាក់ និងតាមដានចំណូល ចំណាយរបស់រតនាគារថ្នាក់មូលដ្ឋាន
- សម្របសម្រួលរាល់ការងារពាក់ព័ន្ធរវាងរតនាគារថ្នាក់មូលដ្ឋាន ជាមួយបណ្តានាយកដ្ឋានជំនាញថ្នាក់កណ្តាលនៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រមូលផ្តុំព័ត៌មានគណនេយ្យនិងស្ថិតិដែលបានមកពីនាយកដ្ឋានថ្នាក់កណ្តាលនិងរតនាគារថ្នាក់មូលដ្ឋាន
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស និងឆ្នាំ។

**ប្រការ៣១.-**

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់១និងសរុប

២. ការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់២

៣. ការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់៣។

**ប្រការ៣២.-**

កាវិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់១ និងសរុប មានភារកិច្ចដូចតទៅ÷

- ពិនិត្យតាមដានកិច្ចដំណើរការរបស់រតនាគាររាជធានី ខេត្តមួយចំនួន
- ធ្វើផែនការចំណូល ចំណាយសាច់ប្រាក់ប្រចាំខែ
- តាមដានការអនុវត្តផែនការចំណូល ចំណាយសាច់ប្រាក់ប្រចាំថ្ងៃ ខែ ឆ្នាំ
- ពិនិត្យការផ្ទេរមូលនិធិរវាងថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- រៀបចំការផ្ទេរសាច់ប្រាក់សម្រាប់ឃុំ សង្កាត់ និងសម្រាប់ថវិកាក្រៅពីឃុំ សង្កាត់
- ពិនិត្យការផ្ទេរអាណត្តិបើកប្រាក់ទូទាត់ពីថ្នាក់មូលដ្ឋាន មកថ្នាក់កណ្តាល
- ពិនិត្យតុល្យភាពសាច់ប្រាក់របស់រតនាគារថ្នាក់មូលដ្ឋាន ប្រចាំថ្ងៃ ខែ
- សម្របសម្រួលរាល់ការងារពាក់ព័ន្ធរវាងរតនាគារថ្នាក់មូលដ្ឋាន ជាមួយនាយកដ្ឋានជំនាញថ្នាក់កណ្តាល នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រមូលផ្តុំព័ត៌មានគណនេយ្យ ស្ថិតិ ពីរតនាគារថ្នាក់មូលដ្ឋាន ប្រចាំថ្ងៃ ខែ ឆ្នាំ
- រៀបចំតារាងស្ថិតិនិងរបាយការណ៍
- ប្រមូលផ្តុំព័ត៌មានគណនេយ្យ ស្ថិតិ ពីបណ្តានាយកដ្ឋាននិងអង្គភាពថ្នាក់កណ្តាល និងការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់១និងសរុប តំបន់២ និងតំបន់៣
- សរុបរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ។

**ប្រការ៣៣.-**

ការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់២ មានភារកិច្ចដូចតទៅ÷

- ពិនិត្យតាមដានកិច្ចដំណើរការរបស់រតនាគាររាជធានី ខេត្តមួយចំនួន
- ធ្វើផែនការចំណូល ចំណាយសាច់ប្រាក់ប្រចាំខែ
- តាមដានការអនុវត្តផែនការចំណូល ចំណាយសាច់ប្រាក់ប្រចាំថ្ងៃ ខែ ឆ្នាំ
- ពិនិត្យការផ្ទេរមូលនិធិរវាងថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- រៀបចំការផ្ទេរសាច់ប្រាក់សម្រាប់ឃុំ សង្កាត់ និងសម្រាប់ថវិកាក្រៅពីឃុំ សង្កាត់
- ពិនិត្យការផ្ទេរអាណត្តិបើកប្រាក់ទូទាត់ពីថ្នាក់មូលដ្ឋាន មកថ្នាក់កណ្តាល
- ពិនិត្យតុល្យភាពសាច់ប្រាក់របស់រតនាគារថ្នាក់មូលដ្ឋាន ប្រចាំថ្ងៃ ខែ
- សម្របសម្រួលរាល់ការងារពាក់ព័ន្ធរវាងរតនាគារថ្នាក់មូលដ្ឋាន ជាមួយនាយកដ្ឋានជំនាញថ្នាក់កណ្តាល នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រមូលផ្តុំព័ត៌មានគណនេយ្យ ស្ថិតិ ពីរតនាគារថ្នាក់មូលដ្ឋាន ប្រចាំថ្ងៃ ខែ ឆ្នាំ
- រៀបចំតារាងស្ថិតិនិងរបាយការណ៍
- រៀបចំរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ ក្នុងការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់២។

**ប្រការ៣៤.-**

ការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់៣ មានភារកិច្ចដូចតទៅ ÷

- ពិនិត្យនិងតាមដានកិច្ចដំណើរការរបស់រតនាគាររាជធានី ខេត្តមួយចំនួន

- ធ្វើផែនការចំណូល ចំណាយសាច់ប្រាក់ប្រចាំខែ
- តាមដានការអនុវត្តផែនការចំណូល ចំណាយសាច់ប្រាក់ប្រចាំថ្ងៃ ខែ ឆ្នាំ
- ពិនិត្យការផ្ទេរមូលនិធិរវាងថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- រៀបចំការផ្ទេរសាច់ប្រាក់សម្រាប់ឃុំ សង្កាត់ និងសម្រាប់ថវិកាក្រៅពីឃុំ សង្កាត់
- ពិនិត្យការផ្ទេរអាណត្តិបើកប្រាក់ទូទាត់ពីថ្នាក់មូលដ្ឋាន មកថ្នាក់កណ្តាល
- ពិនិត្យតុល្យភាពសាច់ប្រាក់របស់រតនាគារថ្នាក់មូលដ្ឋាន ប្រចាំថ្ងៃ ខែ
- សម្របសម្រួលរាល់ការងារពាក់ព័ន្ធរវាងរតនាគារថ្នាក់មូលដ្ឋាន ជាមួយនាយកដ្ឋានជំនាញថ្នាក់កណ្តាល នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រមូលផ្តុំព័ត៌មានគណនេយ្យ ស្ថិតិ ពីរតនាគារថ្នាក់មូលដ្ឋាន ប្រចាំថ្ងៃ ខែ ឆ្នាំ
- រៀបចំគំរូតារាងស្ថិតិនិងរបាយការណ៍
- រៀបចំរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ ក្នុងការិយាល័យគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋានតំបន់៣។

## ជំពូកទី៨
## នាយកដ្ឋានព័ត៌មានវិទ្យា

**ប្រការ៣៥.-**

នាយកដ្ឋានព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារព័ត៌មានវិទ្យា ដោយមានភារកិច្ចដូចតទៅ ÷

- ចូលរួមរៀបចំនិងសម្របសម្រួលការអនុវត្តគម្រោង ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ឬហៅថា FMIS (Financial Management Information System)
- អភិវឌ្ឍយុទ្ធសាស្ត្រនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- កសាងគោលនយោបាយនិងនីតិវិធីព័ត៌មានវិទ្យា
- រៀបចំនិងថែរក្សាប្រព័ន្ធត្រួតពិនិត្យនិងប្រព័ន្ធសុវត្ថិភាពផ្នែកព័ត៌មានវិទ្យា
- គ្រប់គ្រងកិច្ចសន្យាដែលបានធ្វើជាមួយអ្នកផ្តល់សេវាឬអ្នកផ្គត់ផ្គង់
- វិភាគមុខងារនិងតម្រូវការតាមនាយកដ្ឋាននីមួយៗ
- រៀបចំរបាយការណ៍និងតាមដានការអនុវត្តកម្មវិធីស្តីពីព័ត៌មានវិទ្យា
- រៀបចំកម្មវិធីនិងបណ្តុះបណ្តាលព័ត៌មានវិទ្យាដល់ថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន។

**ប្រការ៣៦.-**

នាយកដ្ឋានព័ត៌មានវិទ្យា មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យព័ត៌មានវិទ្យាថ្នាក់កណ្តាល

២. ការិយាល័យព័ត៌មានវិទ្យាថ្នាក់មូលដ្ឋាន

៣. ការិយាល័យព័ត៌មានវិទ្យាសរុប។

**ប្រការ៣៧.-**

ការិយាល័យព័ត៌មានវិទ្យាថ្នាក់កណ្តាល មានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំនិងសម្របសម្រួលការអនុវត្តគម្រោង FMIS
- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់កណ្តាល
- សិក្សាអំពីផែនការមេសម្រាប់ភ្ជាប់យុទ្ធសាស្ត្រក្នុងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់កណ្តាល
- បែងចែកផែនការសកម្មភាពសម្រាប់អនុវត្ត នៅតាមបណ្តានាយកដ្ឋាននិងអង្គភាពនៃអគ្គនាយកដ្ឋានរតនាគារជាតិ
- រៀបចំយន្តការផ្ទេរទិន្នន័យពីថ្នាក់មូលដ្ឋានមកថ្នាក់កណ្តាល
- រៀបចំបណ្តាញ (Network) នៃប្រព័ន្ធត្រួតពិនិត្យនិងសុវត្ថិភាពព័ត៌មានវិទ្យានៅថ្នាក់កណ្តាល
- បង្កើតនិងធ្វើបច្ចុប្បន្នភាពចំពោះគេហទំព័ររបស់អគ្គនាយកដ្ឋានរតនាគារជាតិ
- បង្កើតនិងបែងចែកសិទ្ធិនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់នាយកដ្ឋាននីមួយៗ
- បណ្តុះបណ្តាលសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងគណនេយ្យសាធារណៈនៅថ្នាក់កណ្តាល
- សិក្សាអំពីតម្រូវការប្រព័ន្ធព័ត៌មានវិទ្យាតាមផ្នែកដែលពាក់ព័ន្ធនៅថ្នាក់កណ្តាល
- តាមដានការអនុវត្តកម្មវិធីព័ត៌មានវិទ្យានិងរៀបចំរបាយការណ៍នៅថ្នាក់កណ្តាល។

**ប្រការ៣៨.-**

ការិយាល័យព័ត៌មានវិទ្យាថ្នាក់មូលដ្ឋាន មានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំនិងសម្របសម្រួលការអនុវត្តគម្រោង FMIS
- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់មូលដ្ឋាន
- រៀបចំបណ្តាញ (Network) នៃប្រព័ន្ធត្រួតពិនិត្យនិងសុវត្ថិភាពព័ត៌មានវិទ្យានៅថ្នាក់មូលដ្ឋាន
- បណ្តុះបណ្តាលសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងគណនេយ្យសាធារណៈនៅថ្នាក់មូលដ្ឋាន
- សិក្សាអំពីតម្រូវការប្រព័ន្ធព័ត៌មានវិទ្យាតាមផ្នែកដែលពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន
- តាមដានការអនុវត្តកម្មវិធីព័ត៌មានវិទ្យានិងរៀបចំរបាយការណ៍នៅថ្នាក់មូលដ្ឋាន
- បង្កើតយន្តការដើម្បីរៀបចំរបាយការណ៍តុល្យភាពថវិការដ្ឋ ខេត្ត ក្រុង ស្រុក ខណ្ឌ និងថវិកាឃុំ សង្កាត់ ដើម្បីបញ្ជូនមកថ្នាក់កណ្តាល។

**ប្រការ៣៩.-**

ការិយាល័យព័ត៌មានវិទ្យាសរុប មានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំនិងសម្របសម្រួលការអនុវត្តគម្រោង FMIS
- គ្រប់គ្រងកិច្ចសន្យាជាមួយអ្នកផ្តល់សេវាព័ត៌មានវិទ្យា
- ធ្វើការវាយតម្លៃទៅលើកម្មវិធីព័ត៌មានវិទ្យា
- សហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពនានានៃក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំរបាយការណ៍សរុបប្រចាំខែ ឆ្នាំ ដែលបានមកពីការិយាល័យថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន
- ធ្វើស្ថិតិនិងរបាយការណ៍ចំណូល ចំណាយថវិកាសរុបរបស់រតនាគារថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន។

## ជំពូកទី៩

## អធិការកិច្ចរតនាគារ

**ប្រការ៤០.-**

អធិការកិច្ចរតនាគារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារអធិការកិច្ចរតនាគារ ដោយមានភារកិច្ចដូចតទៅ÷

- តាមដាននិងត្រួតពិនិត្យការប្រព្រឹត្តទៅនៃរតនាគារទូទាំងប្រទេស
- ពិនិត្យបញ្ជាក់លម្អិតនូវកិច្ចបញ្ជិកាចំណូល ចំណាយ គណនេយ្យ និងបេឡានៃរតនាគារថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- ចូលរួមសហការជាមួយអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការត្រួតពិនិត្យរតនាគារក្នុងករណីមានសំណើឱ្យចូលរួម
- ចុះធ្វើការត្រួតពិនិត្យបេឡារបស់ភ្នាក់ងារបើកផ្តល់ការចំណាយរបស់រដ្ឋទេយ្យករបុរេប្រទាន និងការគ្រប់គ្រងចំណូលរបស់រដ្ឋទេយ្យករចំណូលនៃក្រសួង ស្ថាប័ន
- ទទួលពាក្យបណ្តឹងតវ៉ានិងចូលរួមដោះស្រាយរាល់បាតុភាពខុសឆ្គងរបស់មន្ត្រីរាជការរតនាគារ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យរបស់ខ្លួន។

**ប្រការ៤១.-**

អធិការកិច្ចរតនាគារ មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យអធិការកិច្ចរតនាគារទី១និងសរុប

២. ការិយាល័យអធិការកិច្ចរតនាគារទី២

៣. ការិយាល័យអធិការកិច្ចរតនាគារទី៣។

**ប្រការ៤២.-**

ការិយាល័យអធិការកិច្ចរតនាគារទី១និងសរុប មានភារកិច្ចដូចខាងក្រោម÷

- ត្រួតពិនិត្យកិច្ចបញ្ជិកាចំណូល ចំណាយ និងគណនេយ្យរតនាគាររាជធានី ខេត្ត មួយចំនួន
- ត្រួតពិនិត្យតារាងតុល្យភាព តារាងតុល្យការរតនាគាររាជធានី ខេត្ត មួយចំនួន
- តាមដាននិងត្រួតពិនិត្យកិច្ចដំណើរការនិងការប្រព្រឹត្តទៅរបស់រតនាគាររាជធានី ខេត្ត មួយចំនួន
- ចូលរួមសហការជាមួយអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការត្រួតពិនិត្យរតនាគារក្នុងករណីមានសំណើឱ្យចូលរួម
- ទទួលពាក្យបណ្តឹងតវ៉ា និងចូលរួមដោះស្រាយរាល់បាតុភាពខុសឆ្គងរបស់មន្ត្រីរាជការ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យរបស់ខ្លួន
- រៀបចំរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ សរុប ក្នុងការិយាល័យអធិការកិច្ចរតនាគារទី១ ទី២ និងទី៣។

**ប្រការ៤៣.-**

ការិយាល័យអធិការកិច្ចរតនាគារទី២ មានភារកិច្ចដូចតទៅ÷

- ត្រួតពិនិត្យកិច្ចបញ្ជិកាចំណូល ចំណាយ និងគណនេយ្យរតនាគាររាជធានី ខេត្ត មួយចំនួន

- ត្រួតពិនិត្យតារាងតុល្យភាព តារាងតុល្យការរតនាគាររាជធានី ខេត្ត មួយចំនួន
- ចូលរួមសហការជាមួយអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការត្រួតពិនិត្យរតនាគារក្នុងករណីមានសំណើឱ្យចូលរួម
- ទទួលពាក្យបណ្តឹងតវ៉ានិងចូលរួមដោះស្រាយរាល់បាតុភាពខុសឆ្គងរបស់មន្ត្រីរាជការ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យរបស់ខ្លួន
- រៀបចំរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ ក្នុងការិយាល័យអធិការកិច្ចរតនាគារទី២។

**ប្រការ៤៤.-**

ការិយាល័យអធិការកិច្ចរតនាគារទី៣ មានភារកិច្ចដូចតទៅ÷

- ត្រួតពិនិត្យកិច្ចបញ្ជិកាចំណូល ចំណាយ និងគណនេយ្យរតនាគាររាជធានី ខេត្ត មួយចំនួន
- ត្រួតពិនិត្យតារាងតុល្យភាព តារាងតុល្យការរតនាគាររាជធានី ខេត្ត មួយចំនួន
- ចូលរួមសហការជាមួយអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការត្រួតពិនិត្យរតនាគារក្នុងករណីមានសំណើឱ្យចូលរួម
- ទទួលពាក្យបណ្តឹងតវ៉ានិងចូលរួមដោះស្រាយរាល់បាតុភាពខុសឆ្គងរបស់មន្ត្រីរាជការ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យរបស់ខ្លួន
- រៀបចំរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ ក្នុងការិយាល័យអធិការកិច្ចរតនាគារទី៣។

## ជំពូកទី១០
## អង្គភាពគ្រប់គ្រងសាច់ប្រាក់

**ប្រការ៤៥.-**

អង្គភាពគ្រប់គ្រងសាច់ប្រាក់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងសាច់ប្រាក់ ដោយមានភារកិច្ចដូចតទៅ÷

- កសាងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដោយមានគោលការណ៍ និងនីតិវិធីសម្រាប់អង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន ដើម្បីបង្កើតការព្យាករណ៍លំហូរសាច់ប្រាក់ និងការព្យាករណ៍សមតុល្យសាច់ប្រាក់ចុងថ្ងៃ នៅគណនីទោលរតនាគារឱ្យមានភាពត្រឹមត្រូវនិងទាន់ពេលវេលា
- សហការជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័ន ដើម្បីជំរុញការព្យាករណ៍លំហូរសាច់ប្រាក់របស់រាជរដ្ឋាភិបាល និងសមតុល្យសាច់ប្រាក់ចុងថ្ងៃ នៅគណនីទោលរតនាគារ ឱ្យមានភាពត្រឹមត្រូវនិងទាន់ពេលវេលា
- តាមដានពិនិត្យចំណាយពិតប្រាកដនៃថវិកានិងការទូទាត់សាច់ប្រាក់របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ពិនិត្យសមតុល្យសាច់ប្រាក់ក្នុងគណនីទាំងឡាយ ដែលស្ថិតក្រោមរចនាសម្ព័ន្ធគណនីទោលរតនាគារ រួមទាំងប្រាក់បុរេប្រទានដែលគ្រប់គ្រងដោយប្រព័ន្ធរតនាគារជាតិ

- សហការផ្ទៀងផ្ទាត់ការព្យាករណ៍ចំណូលនិងចំណាយរបស់រាជរដ្ឋាភិបាល ជាមួយអង្គភាពពាក់ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន ដោយរួមបញ្ចូលទាំងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- តាមដាន ពិនិត្យ និងព្យាករណ៍លំហូរសាច់ប្រាក់រយៈពេល៣ខែបន្តបន្ទាប់ និងព្យាករណ៍សម្រាប់នាយកដ្ឋានសំខាន់ៗ របស់ក្រសួង ស្ថាប័ន និងអង្គភាពចំណូល
- តាមដានពិនិត្យចំណូលនិងចំណាយជាក់ស្តែងធៀបនឹងផែនការលំហូរសាច់ប្រាក់ប្រចាំឆ្នាំ ហើយធ្វើការព្យាករណ៍លំហូរសាច់ប្រាក់៣ខែបន្តបន្ទាប់
- តាមដាន ពិនិត្យ និងព្យាករណ៍ស្ថានភាពសាច់ប្រាក់សុទ្ធ ដូចជាសមតុល្យសាច់ប្រាក់ចុងថ្ងៃនៅគណនីទោលរតនាគារ សម្រាប់រយៈពេល ៤សប្តាហ៍ ១២សប្តាហ៍ និង៥២សប្តាហ៍
- រាយការណ៍ជាទៀងរាល់ចុងខែស្តីពីការព្យាករណ៍លំហូរសាច់ប្រាក់ និងស្ថានភាពសាច់ប្រាក់សុទ្ធ និងផ្តល់អនុសាសន៍អំពីសេចក្តីត្រូវការនិងលទ្ធភាពដែលអាចបោះផ្សាយប័ណ្ណរតនាគារ ដើម្បីហិរញ្ញប្បទានបំពេញតម្រូវការសាច់ប្រាក់រយៈពេលខ្លី
- គ្រប់គ្រងគណនីប្រាក់កក់តម្កល់លើទីផ្សារសាធារណៈ និងប្រាក់កក់តម្កល់ជានាសកម្មភាពអាជីវកម្ម ជាប្រាក់រៀលនិងរូបិយប័ណ្ណបរទេស។

## ជំពូកទី១១

## លេខាធិការដ្ឋាន

**ប្រការ៤៦.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើភារកិច្ចដូចតទៅ÷

- រៀបចំ ចងក្រង ថែរក្សារាល់ឯកសាររបស់អគ្គនាយកដ្ឋានរតនាគារជាតិ
- រៀបចំនិងពិនិត្យរាល់ឯកសារ សេចក្តីព្រាងសំណើ សំណុំលិខិតផ្សេងៗ មុននឹងដាក់ជូនសុំការសម្រេចពីថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានរតនាគារជាតិ
- សម្របសម្រួលការងារជាមួយនាយកដ្ឋាននិងអង្គភាពនានា ដែលស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់គ្រងត្រារបស់អគ្គនាយកដ្ឋានរតនាគារជាតិ។

## ជំពូកទី១២

## រតនាគាររាជធានី ខេត្ត

**ប្រការ៤៧.-**

រតនាគាររាជធានី ខេត្ត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងាររតនាគារ នៅថ្នាក់មូលដ្ឋាន ដោយមានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រងបេឡាថវិកាថ្នាក់មូលដ្ឋាន
- គ្រប់គ្រងគណនីថវិការដ្ឋនៅរាជធានី ខេត្ត និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គណនីប្រាក់បញ្ញើឯកជន គណនីក្រៅថវិកា និងគណនីពិសេសរបស់រតនាគារ
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋ នៅថ្នាក់មូលដ្ឋាន

- ធ្វើតុល្យភាពសាច់ប្រាក់ និងគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋនៅរាជធានី ខេត្ត និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី
- រៀបចំបិទបញ្ជីគណនេយ្យសាធារណៈ នៅថ្នាក់មូលដ្ឋាន
- ធានាតុល្យភាពទូទៅនៃគណនី
- ផ្តល់សេវាដល់គ្រប់មន្ទីរ អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ ការចំណាយផ្សេងៗ ការបើកបៀវត្សរ៍ និងការប្រមូលចំណូល ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

**ប្រការ៤៨.-**

រតនាគាររាជធានី ខេត្ត មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងបុគ្គលិក

២. ការិយាល័យគណនេយ្យ

៣. ការិយាល័យឃ្លាំងបេឡា។

**ប្រការ៤៩.-**

ការិយាល័យរដ្ឋបាលនិងបុគ្គលិក មានភារកិច្ចដូចតទៅ÷

- រៀបចំនិងតាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង នៅរតនាគាររាជធានី ខេត្ត
- បញ្ជូនឯកសារ ទទួលលិខិតចេញ ចូល និងរៀបចំចងក្រងទុកដាក់ឯកសារ នៅរតនាគាររាជធានី ខេត្ត
- ពិនិត្យនិងផ្តល់ទិដ្ឋាការបេសកកម្មចេញ ចូល និងតាមដានគ្រប់គ្រងប្រាក់បេសកកម្មរបស់មន្ត្រីរតនាគាររាជធានី ខេត្ត
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ នៅរតនាគាររាជធានី ខេត្ត
- បញ្ជិកាតាមដានប្រាក់ជំពូក គណនី អនុគណនី សម្រាប់កិច្ចដំណើរការរដ្ឋបាលរបស់រតនាគាររាជធានី ខេត្ត
- គ្រប់គ្រង បែងចែក និងបើកផ្តល់ប្រាក់លាភការ ប្រាក់បៀវត្សរ៍ នៅរតនាគាររាជធានី ខេត្ត
- គ្រប់គ្រងសម្ភារៈការិយាល័យ នៅផ្ទៃក្នុងរតនាគាររាជធានី ខេត្ត
- គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា នៅរតនាគាររាជធានី ខេត្ត
- រៀបចំគម្រោងចំណូល ចំណាយថវិការបស់រតនាគាររាជធានី ខេត្ត
- រៀបចំពិធីនិងការប្រជុំនានារបស់រតនាគាររាជធានី ខេត្ត
- រៀបចំបដាពាក្យស្លោក តុបតែងលម្អរតនាគាររាជធានី ខេត្ត នៅពេលមានពិធីបុណ្យជាតិ អន្តរជាតិ
- រៀបចំរចនាសម្ព័ន្ធចាត់តាំង អង្គការលេខ។

**ប្រការ៥០.-**

ការិយាល័យគណនេយ្យ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងនិងតាមដានចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ នៅរតនាគាររាជធានី ខេត្ត
- ពិនិត្យបញ្ជាក់អាណត្តិបើកប្រាក់និងលិខិតយុត្តិការភ្ជាប់តាមអាណត្តិបើកប្រាក់
- បញ្ជិកាតាមដានប្រាក់បុរេប្រទាន រជ្ជទេយ្យបុរេប្រទាន និងចំណាយតាមកិច្ចសន្យា
- ចុះកិច្ចបញ្ជិកាតាមដានលម្អិតចំណូល ចំណាយថវិការដ្ឋ នៅរាជធានី ខេត្ត និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស និងឆ្នាំ
- ទទួលពិនិត្យ និងប្រមូលផ្ដុំសលាកប័ត្រលេខនា និងសក្ខីប័ត្រគណនេយ្យ
- រៀបចំឯកសារទាក់ទងនឹងការផ្ទេរនិងទទួលសាច់ប្រាក់រវាងរតនាគារថ្នាក់កណ្ដាល និងរតនាគារថ្នាក់មូលដ្ឋាន
- រៀបចំឯកសារទាក់ទងនឹងការផ្ទេរប្រតិបត្តិការរវាងរតនាគារថ្នាក់កណ្ដាល និងរតនាគារថ្នាក់មូលដ្ឋាន
- គ្រប់គ្រងគណនីប្រាក់បញ្ញើរបស់មន្ទីរ អង្គភាពចំណុះមន្ទីរ អង្គភាពស្វយ័ត សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- គ្រប់គ្រងគណនីប្រាក់បញ្ញើផ្សេងៗទៀត
- គ្រប់គ្រងគណនីចរន្តនៅធនាគារ នៅរតនាគាររាជធានី ខេត្ត
- រៀបចំបែបបទទូទាត់ជូនអត្ថគាហក
- ចុះកិច្ចបញ្ជិកាគណនេយ្យថវិការដ្ឋ (មន្ទីរ) និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំតារាងតុល្យភាពគណនីនិងរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំខែ ឆ្នាំ ថវិកាជាតិនិងថ្នាក់ក្រោមជាតិ
- ធ្វើរបាយការណ៍ផ្សេងៗ តាមតម្រូវការចាំបាច់។

**ប្រការ៥១.-**

ការិយាល័យឃ្លាំងបេឡា មានភារកិច្ចដូចតទៅ÷

- ធ្វើប្រតិបត្តិការចំណូល ចំណាយសាច់ប្រាក់
- ទុកដាក់ ថែរក្សា ការពារសាច់ប្រាក់
- ធ្វើការផ្ទៀងផ្ទាត់តួលេខក្នុងឯកសារនៃកិច្ចប្រតិបត្តិការជាមួយនឹងសាច់ប្រាក់ជាក់ស្ដែងដែលមានក្នុងឃ្លាំងបេឡា ប្រចាំថ្ងៃ
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស ឆ្នាំ។

## ជំពូកទី១៣

## អវសានប្បញ្ញត្តិ

**ប្រការ៥២.-**

ក្នុងពេញបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬស្នើសុំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើ ការកំណត់ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៥៣.-**

ខ្លឹមសារដែលមានក្នុងប្រកាសដូចខាងក្រោម ត្រូវទុកជានិរាករណ៍÷

- ប្រកាសលេខ ៦១៥ សហវ.ប្រក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្ដីពីការផ្ទេរអង្គភាពគ្រប់គ្រងសាច់ប្រាក់ទៅស្ថិតនៅក្នុងអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រកាសលេខ ១០១៥ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០១៦ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋានចំណូលនិងចំណាយថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ប្រកាសលេខ ១០១៧ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋានគណនេយ្យនៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០១៨ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋានគ្រប់គ្រងបេឡានិងបំណុលនៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០១៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០២០ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០២១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១០២២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃរតនាគារថ្នាក់មូលដ្ឋាន នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៥៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ១៤៤២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៣

អង្គការលេខរបស់អគ្គនាយកដ្ឋានរតនាគារជាតិ - ថ្នាក់កណ្តាល

